សាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្តនិងវិទ្យាសាស្រ្តសេដ្ឋកិច្ច
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# ការបង្កើត និង ការរំលាយកិច្ចសន្យា

ស្រាវជ្រាវពីថ្ងៃទី ២៧ ខែមេសា ឆ្នាំ២០២១ ដល់ថ្ងៃទី ២៥ ខែមិថុនា ឆ្នាំ២០២១

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ លោក **អ៊ុំ ជីស៊ីញ**
លោក **ង៉ា សីហាន**

សាស្ត្រាចារ្យណែនាំ
អ្នកស្រី **ទី សុឃីតា**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី ២១

ឆ្នាំចូលសិក្សា ២០១៧
ឆ្នាំសរសេរសារណា ២០២១

# សេចក្តីថ្លែងអំណរគុណ

ជាបឋមខ្ញុំបាទឈ្មោះ **អ៊ី ជីស៊ីញ** និង ខ្ញុំបាទឈ្មោះ **ទ៉ា សីហាន** សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះអ្នកមានគុណទាំងពីរ **លោកឪពុក** និង **អ្នកម្តាយ** ជាទីគោរពបានផ្តល់ជំរកដល់កក់ក្តៅ ដែលលោកទាំងពីរមានគុណធំធេងជាងមហាសមុទ្រ ពុំអាចថ្លែងបាន។ លោកទាំងពីរបានបង្កើតកូនមកបានឃើញពន្លឺថ្ងៃជាមួយនឹងពិភពលោកដ៏ស្រស់បំព្រង លោកទាំងពីរបានបីបាច់បានបំពេញកាតព្វកិច្ចជាអាណាព្យាបាលដ៏ល្អ តែងតែស្រឡាញ់ថ្នាក់ថ្នម ប្រៀនប្រដៅ បណ្តុះផ្នត់គំនិតឲ្យកូនបានជាកូនល្អដោយក្រមសីលធម៌ និងជាមនុស្សល្អ ដែលសង្គមមិនស្អប់ខ្ពើម។ លោកទាំងពីរបាននាំកូនចូលរៀនបឋមសិក្សាតាំងពីអាយុ៦(ប្រាំមួយ) ដល់អនុវិទ្យាល័យ ដល់វិទ្យាល័យ បានបញ្ចប់សញ្ញាប័ត្រទុតិយភូមិ បានផ្តល់ឪកាសឲ្យកូនបន្តទៅសិក្សាសាកលវិទ្យាល័យ។ លោកទាំងពីរបានបញ្ចេញកម្លាំងចិត្ត កម្លាំងកាយចំពោះថវិកាដែលលោកបានផ្តល់តាំងសម្ភារៈ យានជំនិះ ទោះលំបាកពិនណាក៏មិនអោយកូនដឹងខំជូនកូនរហូតពេលចុងក្រោយបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាប័ត្រមួយនេះសម្រេចគោលបំណង និងចងឃើញកូនបំពេញបំណងខ្លួនឯង ជោគជ័យក្នុងជីវិតអរគុណសម្រាប់ទឹកចិត្តដ៏ថ្លៃថ្លារបស់លោកពិតជាច្រើនខ្លាំងណាស់ពិតជាមិនអាចកាត់ថ្លៃបាន។

យើងខ្ញុំជាសូមថ្លែងអរគុណដ៏ខ្ពង់ខ្ពស់គោរពជូនគោរពជូន **ឯកឧត្តម លុយ ចណ្ណា** ជាសកលវិទ្យាធិការ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដោយលោកបានយកចិត្តទុកដាក់ក្នុងការគ្រប់គ្រងយ៉ាងម៉ត់ចត់ ធ្វើយ៉ាងណាឲ្យសាកលវិទ្យាល័យមួយនេះ មានការរីកចម្រើន និងអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព។ សូមគោរពអរគុណដល់ លោកគ្រូ អ្នកគ្រូ ដែលជាសាស្ត្រាចារ្យ ដែលបានបង្ហាត់បង្រៀនយ៉ាងយកចិត្តទុកដាក់ ក្នុងការចែករំលែកនូវបទពិសោធន៍ និងដំបូន្មានល្អៗ ចាប់តាំងពីថ្នាក់មូលដ្ឋាននៃការសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្រ្ត រហូតដល់បញ្ចប់នៃការសិក្សាឆ្នាំទី៤នេះ។

ក្នុងនាមជានិស្សិតយើង ខ្ញុំសូមបញ្ចេញថ្លែងអំណរគុណដល់ លោកស្រីសាស្ត្រាចារ្យ **ទី សុឃីតា** ដែលបានចំណាយពេលដល់មានតម្លៃ ក្នុងការបង្ហាត់ណែនាំដល់យើងខ្ញុំ ចំពោះការសរសេរសារណាបញ្ចប់ការសិក្សាបរិញ្ញាបត្រ ផ្នែកនីតិសាស្រ្តរហូតបានជោគជ័យ។

ជាចុងក្រោយក្រោយ យើងខ្ញុំសូមលើកម្រាមដៃដប់ប្រណម បួងសួងដល់វត្ថុសក្តិសិទ្ធិ ទេព្តា ក្នុងលោក សូមប្រសិទ្ធិពរជ័យសិរិសួស្តីជូនចំពោះ លោកឪពុក អ្នកម្តាយ ឯកឧត្តម សាកលវិទ្យាធិការ សាស្ត្រាចារ្យលោកគ្រូ អ្នកគ្រូ បងប្អូន មិត្តភក្តិ សូមជួបប្រទះតែសេចក្តីសុខសប្បាយ សុខភាពល្អ សុភមង្គល ជោគជ័យគ្រប់ភារកិច្ច ព្រមទាំងជួបប្រទះតែពុទ្ធប្រពរទាំងឡាយ ៤ប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈកុំបីឃ្លៀងឃ្លាតឡើយ

# អារម្ភកថា

នៅក្នុងសង្គមរស់នៅនាពេលបច្ចុប្បន្ន យើងខ្ញុំបានមើលឃើញថា ការទំនាក់ទំនងរវាងបុគ្គលនិងបុគ្គល និង បុគ្គលឯក ក៏ដូចជាក្រុមហ៊ុមមានសារៈសំខាន់ខ្លាំងណាស់ និង មានភាពចាំបាច់ក្នុងការវិនិយោគ ក៏ដូចជាតម្រូវការក្នុងការរស់នៅ។ យ៉ាងណាមិញ ការទំនាក់ទំនងទាំងនោះប្រាដកណាស់នឹងនាំឲ្យមាននូវចំណងទាក់ទងគតិយុត្តរវាងគូភាគីដូចនេះរាល់ទំនាក់ទំនងក្នុវិស័យជំនួញ ហើយចាំបាច់ណាស់ក្នុងការតម្រូវឲ្យមានកិច្ចសន្យាច្បាស់លាស់។ នៅក្នុងក្រមរដ្ឋប្បវេណី នៃព្រះរាជណាចក្រកម្ពុជាក៏បានចែងផងដែរនូវប្រភេទនៃកិច្ចសន្យាជាច្រើនដែលមានការប្រើប្រាស់នៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាជនកម្ពុជា។ហេតុដូច្នេះទើបបានជាក្រុមរបស់យើងខ្ញុំធ្វើការជ្រើសរើនូវប្រធានបទស្ដីអំពី "**ការបង្កើតកិច្ចសន្យា និងការរំលាយកិច្ចសន្យា**" ។

ទោះបីជាយ៉ាងណា ក៏យើងខ្ញុំបាទបានខិតខំរកឯកសារថ្មីៗ និង ស្វែងយល់អំពីប្រធានបទមួយនេះឲ្យស៊ីជម្រៅ រហូតដល់យើងខ្ញុំទទួលបាននូវភាពជោគជ័យនៅការសរសេរសារណាមួយនេះ។ នៅក្នុងស្នាដៃនេះបានសរសេររៀបរាប់ពីការប្រាស្រ័យទាក់ទងគ្នា ការបង្កើតតួនាទី កាតព្វកិច្ច ការទទួលខុសត្រូវរបស់គូភាគី និងការរំលាយកិច្ចសន្យាទៅវិញ។ យើងខ្ញុំសង្ឃឹម ស្នាដៃនៃការសិក្សាស្រាវជ្រាវនូវសារណាមួយនេះ និងផ្ដល់ជាឯកសារដែលមានអត្ថប្រយោជន៍ និងចូលរួមលើស្ទួយវិស័យយុត្តិធម៌ វិស័យឯកជនក៏ដូចជា វិស័យផ្សេងៗ និងជាពិសេសជួយឲ្យនីតិរដ្ឋនៅកម្ពុជាកាន់តែរីកចម្រើន។

ទន្ទឹមនឹងនេះផងដែរ យើងខ្ញុះក៏សូមខន្តីអភ័យទោសទុកជាមុខនូវរាល់កំហុសឆ្គាំឆ្គង ដែលកើតមានឡើងដោយអចេតនាណាមួយពីព្រោះថា នៅក្នុងការសិក្សាស្រាវជ្រាវតែងតែមាននូវចំណុចខ្វះខាតមួយចំនួនជាក់ជាមិនខានគ្រាន់តែកំហុសមានតិច ឬច្រើនប៉ុណ្ណោះទាំងអក្ខរាវិរុទ្ធក្ដី ទាំងពាក្យពេចន៍ និងទាំងអត្ថន័យក្ដី។ ដូច្នេះហើយ យើងខ្ញុំរងចាំជានិច្ចនូវ រាល់មតិរិះគន់ដើម្បីស្ថាបនាដោយក្ដីរីករាយ អំពីសំណាក់លោកស្រ្តាចារ្យ ក៏ដូចជាមិត្តអ្នកអានទាំងអស់ដែលនឹងកំពុងបានអាននូវសារណារបស់យើងខ្ញុំ។

# មាតិកា

ទំព័រ

**សេចក្តីផ្តើម** .......... 1

**ជំពូកទី១**

**សញ្ញាណទូទៅនៃកិច្ចសន្យា**

**ផ្នែកទី១៖ ច្បាប់គ្រប់គ្រងកិច្ចសន្យា** .......... 2

**ផ្នែកទី២៖ គោលការណ៍សំខាន់ៗនៅក្នុងនីតិកិច្ចសន្យា** .......... 3

២.១.គោលការណ៍ស្វ័យភាពខាងឆន្ទៈ .......... 3

២.២ គោលការណ៍សេរីភាពនៃការចុះកិច្ចសន្យា .......... 3

២.៣ បទប្បញ្ញត្តិតាមការស្ម័គ្រចិត្ត និង បទប្បញ្ញត្តិដោយបង្ខំ .......... 4

**ជំពូកទី២**

**ការបង្កើតកិច្ចសន្យា**

**ផ្នែកទី១៖ គោលការណ៍នៃការបង្កើតកិច្ចសន្យា** .......... 5

១.១ សំណើ .......... 5

១.១.១ លក្ខខណ្ឌនៃសំណើ .......... 5

១.១.១.១ គោលបំណងពិតប្រាកដ .......... 5

១.១.១.២ ភាពច្បាស់លាស់នៃសំណើ .......... 5

១.១.១.៣ ការជូនដំណឹងអំពីសំណើ .......... 6

១.២ ស្វីការ .......... 6

១.២.១ លក្ខខណ្ឌនៃស្វីការ .......... 6

១.២.១.១ អ្នកមានសិទ្ធក្នុងការផ្តល់ស្វីការ .......... 6

១.២.១.២ ការជូនដំណឹងអំពីស្វីការ .......... 6

១.២.១.៣ ស្វីការត្រូវតែធ្វើមុនពេលសំណើរំលត់ .......... 6

១.៣ សមត្ថភាពនៃភាគី .......... 7

១.៤ លក្ខខណ្ឌទម្រង់នៃកិច្ចសន្យា .......... 7

១.៥ ចំណាត់ថ្នាក់នៃកិច្ចសន្យា ........ 8
១.៥.១ កិច្ចសន្យាដែលយកតម្លៃថ្នូរ ........ 8
១.៥.២ កិច្ចសន្យាដែលមិនយកតម្លៃថ្នូរ ........ 8
១.៥.៣ កិច្ចសន្យាទ្វេភាគី ........ 8
១.៥.៤ កិច្ចសន្យាឯកតោភាគី ........ 8
**ផ្នែកទី២៖ លក្ខខណ្ឌដើម្បីបង្កើតអានុភាពនៃកិច្ចសន្យា** ........ 8
២.១.លក្ខខណ្ឌសុពលភាពនៃកិច្ចសន្យា ........ 8
២.១.១ លក្ខខណ្ឌទូរទៅទាក់ទងនឹងភាគី ........ 9
២.១.២ លក្ខខណ្ឌទូទៅទាក់ទងនឹងខ្លឹមសារនៃកិច្ចសន្យា ........ 10
២.២ អានុភាពនៃកិច្ចសន្យា ........ 11
២.២.១ អានុភាពជាចំណង់ និងអានុភាពដោយធៀប ........ 11
២.២.២ សិទ្ធិតវ៉ាឱ្យអនុវត្តព្រមគ្នា ........ 11
២.៣ អានុភាពនៃកិច្ចសន្យាចំពោះភាគី ........ 12
២.៣.១ អានុភាពបង្កើតសិទ្ធិទូទៅចំពោះភាគី ........ 12
២.៣.២ អានុភាពចាប់បង្ខំនូវករណីកិច្ចទូទៅចំពោភាគី ........ 12
២.៣.២.១ កិច្ចសន្យាត្រូវតែអនុវត្ត ........ 13
២.៣.២.២ ការអនុវត្តត្រូវតែគោរពគោលការណ៍សុចរិតនិងស្មោះត្រង់ ........ 14
២.៤ អានុភាពបង្កើតជាច្បាប់របស់ភាគី ........ 15
២.៤.១ ភាពមិនអាចកែប្រែបាននៃកិច្ចសន្យា ........ 16
២.៤.២ ភាពមិនអាចបំពានបាននៃកិច្ចសន្យា ........ 16
២.៥ កិច្ចសន្យាដែលធ្វើឡើងសម្រាប់តតិយជន ........ 17
២.៦ អានុភាពនៃកិច្ចសន្យាចំពោះតតិយជន ........ 18
២.៦.១ កិច្ចសន្យាដែលបង្កើតស្ថានភាពគតិយុត្តចំពោះតតិយជន ........ 18

# ជំពូកទី៣

# ការរំលាយកិច្ចសន្យា

**ផ្នែកទី១៖ ប្រភពនៃសិទ្ធិរំលាយកិច្ចសន្យា** .......... 21

១.១. សិទ្ធិរំលាយកិច្ចសន្យា ដែលបានកំណត់នៅក្នុងច្បាប់ .......... 21

១.២. សិទ្ធិរំលាយកិច្ចសន្យា ដែលបានកំណត់នៅក្នុងកិច្ចសន្យា .......... 21

១.៣. សិទ្ធិរំលាយកិច្ចសន្យា ដែលផ្អែកលើបញ្ញត្តិពិសេស .......... 21

១.៤. ប្រព័ន្ធប្រហាក់ប្រហែល នឹងការរំលាយកិច្ចសន្យា .......... 22

១.៤.១. ការរំលាយកិច្ចសន្យា ដោយការព្រមព្រៀង .......... 22

១.៥. លក្ខខណ្ឌនៃការរំលាយកិច្ចសន្យា .......... 22

១.៥.១. ការយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ច .......... 23

១.៥.២. អលទ្ធភាពក្នុងការអនុវត្តកាតព្វកិច្ចដែលមានពេលកំណត់ .......... 23

១.៥.៣. អលទ្ធភាពក្នុងការអនុវត្តកាតព្វកិច្ច .......... 23

១.៥.៤. ការបាត់បង់ទំនុកចិត្តរវាងភាគី .......... 24

១.៦. វិធីអនុវត្តសិទ្ធិរំលាយកិច្ចសន្យា .......... 24

**ផ្នែកទី២៖ អានុភាពនៃការរំលាយកិច្ចសន្យា** .......... 25

២.១. ការរលត់នូវករណីយកិច្ចក្នុងកិច្ចសន្យា .......... 26

២.២. ករណីយកិច្ចធ្វើបដិទានឲ្យគ្នាទៅវិញទៅមក .......... 27

២.៣. ទំហំនៃករណីយកិច្ចធ្វើបដិទាន .......... 27

២.៤. ការការពារតតិយជន .......... 27

២.៥. ការរលត់នូវសិទ្ធិរំលាយកិច្ចសន្យា .......... 28

២.៥.១. ការអនុវត្តកាតព្វកិច្ច ឬសំណើផ្តល់ការអនុវត្តកាតព្វកិច្ច .......... 28

២.៥.២. ការខូចខាតកម្មវត្ថុនៃកិច្ចសន្យា .......... 29

២.៥.៣. ការរលត់នូវសិទ្ធរំលាយកិច្ចសន្យាដោយអាជ្ញាយុកាល .......... 29

**សេចក្តីសន្និដ្ឋាន និង អនុសាសន៍** .......... 31

## ឯកសារយោង

## ឧបសម្ព័ន្ធ

# សេចក្តីផ្តើម

កិច្ចសន្យា ត្រូវបានប្រើប្រាស់តាំងពីសម័យបុរាណ ដើម្បីធានាចំពោះការអនុវត្តកិច្ចសន្យារបស់ភាគីផ្សេងៗ។ ច្បាប់កិច្ចសន្យា ចាប់ផ្តើមចេញរូបរាងនៅសតវត្សទី១៥ នៅប្រទេសអង់គ្លេស បន្ទាប់មកនៅក្នុងបដិវត្តន៍ឧស្សាហកម្ម នៅសតវត្សទី១៩ ការកើនឡើងភាពស្មុគស្មាញនៃកិច្ចសន្យា រួមជាមួយគំនិតថ្មីនៃសេដ្ឋកិច្ចទីផ្សារសេរី បានបង្កើតឡើងនៅច្បាប់កិច្ចសន្យាថ្មីមួយ។ ច្បាប់កិច្ចសន្យានេះ កើតឡើងពីគំនិត "សេរីភាពនៃការបង្កើតកិច្ចសន្យា" ដោយបុគ្គលឯកជន គួរតែបង្កើតកិច្ចសន្យាដោយឯករាជ្យ ដោយគ្មានការជ្រៀតជ្រែកពីអ្នកដទៃ ហេតុដូច្នេះតុលាការមានតួនាទីបង្ខំគូភាគីអនុវត្តការសន្យាហើយតុលាការពុំសម្រេចទៅលើភាពត្រឹមត្រូវ ឬភាពខុសនៃកិច្ចសន្យាទេ។ ការផ្តល់សេរីភាពខ្លាំងពេក ក្នុងការបង្កើតកិច្ចសន្យាអោយទៅភាគីនៃកិច្ចសន្យា ក៏បានកើតជាបញ្ហាឡើងដោយសារ ភាគីដែលមានអំណាចតែងតែកេងចំណេញទៅលើភាគីម្ខាងទៀត។

កិច្ចសន្យា ត្រូវបានបង្កើតឡើងដោយចាប់ផ្តើមមានស្តង់ដាហើយបន្ថយសេរីភាពនៃការបង្កើតកិច្ចសន្យារបស់គូភាគីនៅពាក់កណ្តាលនិងចុងសតវត្សទី២០ ដោយសារការវិវឌ្ឍន៍នេះហើយតុលាការអាចបកស្រាយកិច្ចសន្យាដោយយោងទៅតាមហេតុសមភាព និង យុត្តិធម៌ ជាលទ្ធផលមានការពារចំពោះភាគីទន់ខ្សោយខ្លាំងជាងមុន។

ចំណែកឯ ច្បាប់របស់ប្រទេសកម្ពុជាវិញ (រួមទាំងច្បាប់កិច្ចសន្យា) ត្រូវបានវិវឌ្ឍន៍ពីច្បាប់ទំនៀមទំលាប់នៅសម័យបុរាណមកច្បាប់សម័យទំនើប ដែលមានការចងក្រងដោយយកលំនាំតាមច្បាប់របស់ប្រទេសបារាំង ក្រោយឆ្លងកាត់សម័យជាច្រើន ច្បាប់កិច្ចសន្យាមានការវិវឌ្ឍន៍យ៉ាងខ្លាំង។ បច្ចុប្បន្ននេះ ច្បាប់កិច្ចសន្យា ត្រូវបានចែងក្នុងក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ដោយយកលំនាំតាមច្បាប់របស់ប្រទេសជប៉ុន។

ក្រោយពេលរំដោះប្រទេស ចេញពីរបបប្រល័យពូជសាសន៍ នៅឆ្នាំ១៩៧៩ រហូតមកដល់ពេលបច្ចុប្បន្ននេះ ប្រភពចំបងនៃច្បាប់កិច្ចសន្យាគឺ៖

-ក្រឹត្យ ច្បាប់ លេខ៣៨ ក្រ.ច ស្តីអំពី កិច្ចសន្យា និង ការទទួលខុសត្រូវក្រៅកិច្ចសន្យាឆ្នាំ១៩៨៨។

-ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

ក្រឹត្យ ច្បាប់ លេខ៣៨ ក្រ.ច ស្តីអំពី កិច្ចសន្យា និង ការទទួលខុសត្រូវ ក្រៅកិច្ចសន្យាឆ្នាំ១៩៨៨ គឺជាមូលដ្ឋានគ្រឹះនៃ នីតិកាតព្វកិច្ច នីតិកិច្ចសន្យា ក៏ដូចជាការទទួលខុសត្រូវក្រៅកិច្ចសន្យា របស់ប្រទេសកម្ពុជា។ នៅសម័យឆ្នាំ១៩៨៨ ក្រឹត្យច្បាប់លេខ៣៨ ក្រ.ច នេះមានសារសំខាន់ណាស់ ដោយត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយ រហូតមកដល់ពេលដែល ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ ត្រូវបានគេយកមកប្រើប្រាស់វិញ។

ចំណែកឯ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ ត្រូវបានចាត់ទុកថាជា ក្រមដ៏មានសារៈ សំខាន់មួយនៃនីតិឯកជន ដោយហេតុថាក្រមនេះ គឺជាច្បាប់មូលដ្ឋាន ឬជាច្បាប់រួម ដែល អនុវត្តគ្រប់ទំនាក់ទំនងគតិយុត្ត ក្នុងនីតិឯកជន លើកលែងតែ មានច្បាប់ពិសេស។

នៅឆ្នាំ២០១១ រាជរដ្ឋាភិបាលកម្ពុជាប្រកាសឱ្យ អនុវត្តក្រមរដ្ឋប្បវេណី និងច្បាប់ស្តីពី ការអនុវត្តក្រមរដ្ឋប្បវេណីរួចមក បទប្បញ្ញត្តិនៃក្រឹត្យ-ច្បាប់លេខ ៣៨ ដែលនៅជាធរមាននោះ គឺមានតែមាត្រា ៨៣ ដល់មាត្រា ៨៤ ពោលគឺជាមាត្រាដែល ពាក់ព័ន្ធនឹងកិច្ចសន្យា ដឹកជញ្ជូន តែប៉ុណ្ណោះ ។

# ជំពូកទី១
# សញ្ញាណទូទៅនៃកិច្ចសន្យា

## ផ្នែកទី១៖ ច្បាប់គ្រប់គ្រងកិច្ចសន្យា

គូភាគីជ្រើសរើសច្បាប់គ្រប់គ្រងការបកស្រាយកិច្ចសន្យា ឬជាច្បាប់សារធាតុនៃកិច្ចសន្យា។ ជាធម្មតា គូរភាគីជ្រើសរើសច្បាប់សារធាតុមួយ នៃរដ្ឋរបស់ភាគីណាមួយនៃកិច្ចសន្យាសម្រាប់ពង្រាង និងដោះស្រាយទំនាស់ដែលកើតចេញពីឬមានទំនាក់ទំនងជាមួយកិច្ចសន្យា។ ជួនកាលគូភាគីអាចជ្រើសរើស ច្បាប់ចំណុចកណ្ដាលមួយដែលច្បាប់នោះមានការទទួលស្គាល់ជាអន្តរជាតិ ជាតួយ៉ាងគេអាចជ្រើសរើសអនុសញ្ញាអង្គការសហប្រជាជាតិស្ដីពីកិច្ចសន្យាសម្រាប់ការលក់ទំនិញអន្តរជាតិ (CISG) ជាច្បាប់សារធាតុគ្រប់គ្រងទំនាស់លើការទិញលក់ទំនិញឆ្លងប្រទេស។ ទោះបីជាគូភាគីជ្រើសរើសច្បាប់អន្តរជាតិគំរូណាមួយក៏ដោយ ក៏គេគួរជ្រើសរើសច្បាប់ជាតិណាមួយដើម្បីបំពេញភាពខ្វះខាតនៃទំនាក់ទំនងក្នុងកិច្ចសន្យា។[1] ការខ្វះខាតនោះក្នុងផ្នែកទិញលក់ទំនិញអាចមានដូចជា ៖ ស្ដីពីសុពលភាពនៃកិច្ចសន្យា ឬផលប៉ះពាល់របស់កិច្ចសន្យាលើទំនិញដែលត្រូវលក់។[2] ជាតួយ៉ាងក្រមរដ្ឋប្បវេណីនៃប្រទេសកម្ពុជា ឆ្នាំ២០០៧ មាន ខលម្អិតជាច្រើនដែលដោះស្រាយទំនាក់ទំនងនៃការទិញលក់។[3]

ផ្ទុយពីទិដ្ឋភាពពីរទៀត (ច្បាប់គ្រប់គ្រងកិច្ចព្រមព្រៀងមជ្ឈត្តការ និងច្បាប់គ្រប់គ្រងនីតិវិធីមជ្ឈត្តការពាណិជ្ជកម្ម)ទាក់ទងនឹងកិច្ចព្រមព្រៀងមជ្ឈត្តការ និងនីតិវិធីនៃការធ្វើមជ្ឈត្តការ វិធានស្ដីពីការសម្រេចលើការអនុវត្តច្បាប់លើកិច្ចសន្យាមានចែងក្នុងមាត្រា២៨ នៃច្បាប់គំរូអង្គការសហប្រជាជាតិ (UNCITRAL)។ មាត្រានេះពន្យល់ថា គូភាគីមានសេរីភាពក្នុងការ ជ្រើសរើសច្បាប់គ្រប់គ្រងទំនាស់ ហើយមជ្ឈត្តករមានកាតព្វកិច្ចធ្វើតាមជម្រើសរបស់គូភាគី។[4] មាត្រា៣៦ នៃច្បាប់ស្ដីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម នៃប្រទេសកម្ពុជា តម្រូវឱ្យវេទិកាសម្រេចពី វិវាទមួយទៅតាមវិធាននៃច្បាប់ដែលជ្រើសរើសដោយភាគីវិវាទ និងដែលអនុវត្តបានចំពោះកម្មវត្ថុនៃវិវាទនោះ។

កិច្ចសន្យា ជាការសម្ដែងឆន្ទៈព្រមព្រៀងរវាងបុគ្គលពីរនាក់ ឬ ច្រើននាក់ដើម្បីបង្កើតកែប្រែ ឬ រំលត់កាតព្វកិច្ចមួយ ឬ ច្រើនដែលទាក់ទងនិងខ្លួន ។ ក្នុងអត្ថន័យខាងលើ បុគ្គលអាចជារូបវន្តបុគ្គល ឬ នីតិបុគ្គល ។ [5] ការសម្ដែងឆន្ទៈ មានន័យថាជាការប្រាប់ចេតនារបស់យើងទៅអ្នកដទៃ ឬ ដៃគូដើម្បីបង្កើតចំណងផ្លូវច្បាប់ក្នុងកម្រិតមួយដែលស្របទាំងស្រុងទៅតាមឆន្ទៈដែលត្រូវបានបង្កើតឡើងនោះ ។

---

[1] The Prinicples and Practice of International Commercial Arbitration. Margaret L. Moses. p 69. Para 3 (ឯកសារបស់លោកមេធាវី គឹម សាន)

[2] The Prinicples and Practice of International Commercial Arbitration. Margaret L. Moses. p 69. Para 3 (ឯកសារបស់លោកមេធាវី គឹម សាន)

[3] គន្ថីទី៥ ជំពូកទី១ ស្ដីពីការលក់ ទិញ នៃក្រមរដ្ឋប្បវេណី ២០០៦ មាន៥០មាត្រា (ពីមាត្រា ៥១៥ ដល់ ៥៦៥ ) អាចប្រើប្រាស់បានក្នុងទំនាកទំនងលក់ទិញ (ឯកសារបស់លោកមេធាវី គឹម សាន)

[4] សូមមើលមាត្រា ២៨ នៃច្បាប់គម្រូអង្គាសហប្រជាជាតិ (UNCITRAL)

[5] មាត្រា ១ នៃក្រឹត្យ-ច្បាប់លេខ ៣៨

សូមកុំគិតថា ការប្រាប់នូវអ្វីៗដែលខ្លួនយល់ឃើញទៅដៃគូទាំងប៉ុន្មាន សុទ្ធតែជាការសម្តែងឆន្ទៈនោះឱ្យសោះ ។ តាមច្បាប់គ្រប់ការសម្តែងឆន្ទៈ មិនមែនសុទ្ធតែបង្កើតឱ្យមានអានុភាពគតិយុត្តនោះទេ ។ ឧទាហរណ៍ថាយើងបានពោលពាក្យពេចន៍ ស្នេហារៀបរាប់នូវមនោសញ្ចេតនាទៅសង្សាររបស់ខ្លួននៅពេលនោះ ទោះបីជាយើងបាននិយាយដោយមានការតាំងចិត្តមោះមុតយ៉ាងណាក៏ដោយ ទាំងនេះមិនមែនមានន័យថាជាការសម្តែងឆន្ទៈដូចដែលបានអធិប្បាយនោះទេ ។ ផ្ទុយទៅវិញ ក្នុងករណីដែលយើងបានហុចប្រាក់ ១០០០រៀល ទៅឱ្យម្ចាស់តូប ហើយនិយាយថា "ឱ្យកូកាកូឡានេះមកខ្ញុំ នេះជាការសម្តែងឆន្ទៈដ៏ជាក់លាក់ និង ច្បាស់លាស់មួយ ។ ពីព្រោះថានេះជាសំណើដើម្បីបង្កើតកិច្ចសន្យាទិញកូកាកូឡាក្នុងតម្លៃ ១០០០ រៀលហើយ ប្រសិនបើអ្នកលក់យល់ព្រមតាមសំណើនោះ ខណៈនោះចំណងផ្លូវច្បាប់និងកើតមានរវាងអ្នកលក់ និង អ្នកទិញ ហើយនិងនាំមកនូវការកកើតកាតព្វកិច្ចរវាងភាគីទាំងពីរ ។

តាមក្រមរដ្ឋប្បវេណីសង្គមចាស់ មាត្រា ៧៩១ កិច្ចសន្យា ជាកិរិយាដែលជនពីរនាក់ ឬ ច្រើននាក់មានឆន្ទៈត្រូវគ្នា ព្រមបង្កើត កែប្រែ ឬ លំត់នូវកាតព្វកិច្ចមួយ ឬ ច្រើនដែលជាបន្ទុកលើខ្លួនម្នាក់ៗ ។ កិច្ចសន្យានោះអាចចែងពីកាតព្វកិច្ចពិសេសដែលជាបន្ទុកលើភាគីតែម្នាក់ ឬ ច្រើននាក់ឱ្យបំពេញក៏បាន ឬ អាចចែងពីកាតព្វកិច្ចទៅវិញទៅមក ដែលជាបន្ទុកលើភាគីទាំងសងខាងឱ្យបំពេញទៅវិញទៅមកក៏បាន ។

តាមក្រមរដ្ឋប្បវេណីបារាំង មាត្រា ១១០១ កិច្ចសន្យា គឺជាអនុសញ្ញាមួយដែលតាមរយៈនោះភាគីមួយ ឬ ច្រើនបានសន្យាចំពោះភាគីម្ខាងទៀត ឬ ច្រើនដើម្បីឱ្យធ្វើ ឬ មិនធ្វើអ្វីមួយ ។

តាមក្រមរដ្ឋប្បវេណី២០០៧ មាត្រា ៣១១ បានចែងថា កិច្ចសន្យាជាកិរិយាដែលបុគ្គលពីរនាក់ ឬ ច្រើននាក់មានឆន្ទៈត្រូវគ្នាព្រមបង្កើត កែប្រែ ឬ រំលត់នូវកាតព្វកិច្ច ។

## ផ្នែកទី២៖ គោលការណ៍សំខាន់ៗនៅក្នុងនីតិកិច្ចសន្យា

### ២.១.គោលការណ៍ស្វ័យភាពខាងឆន្ទៈ

តាមរយៈគោលការណ៍នេះ គឺផ្តោតធ្ងន់ទៅលើឆន្ទៈរបស់បុគ្គលម្នាក់ៗ ដែលជា ភាគីនៅក្នុងរឿងរដ្ឋប្បវេណី ។ ពោល បុគ្គលម្នាក់ៗ ដែលជាពលរដ្ឋ មិនមែនរស់ដោយគោរពតាមវិធានដែលអ្នកដទៃកំណត់ឱ្យនេះទេ បានន័យថា នៅរាល់ទំនាក់ទំនងជីវភាពរវាងបុគ្គលនិងបុគ្គល ហើយនិងបង្កើតវិធាននៅតាមឆន្ទៈរបស់ខ្លួន ហើយគ្រប់គ្រងជីវភាពរបស់ខ្លួនដោយខ្លួនឯងដែរ ។ នេះគេហៅថា គោលការណ៍ស្វ័យភាពខាងឆន្ទៈ ឬ គោលការណ៍ស្វ័យភាពនៃបុគ្គលឯកជន។[6] តាមរយៈគោលការណ៍នេះ ឆន្ទៈរបស់គូភាគីត្រូវបានយកមកធ្វើជាវិធានច្បាប់ សម្រាប់ធ្វើការគ្រប់គ្រងទំនាក់ទំនងគតិយុត្ត ដោយធ្វើការបដិសេធចោលវិធានច្បាប់ ។

### ២.២ គោលការណ៍សេរីភាពនៃការចុះកិច្ចសន្យា

តាមរយៈគោលការណ៍នេះ គូភាគី អាចធ្វើកិច្ចសន្យាដោយសេរីតាមឆន្ទៈព្រមព្រៀងដោយសេរីនិង ពិតប្រាកដ មានន័យថាការព្រមព្រៀងដោយគ្មានវិការៈ ។ ពោលគឺគូភាគី អាចបង្កើតកិច្ចសន្យាដោយសេរីកុំឱ្យតែប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ និង ទំនៀមទំលាប់នៅក្នុងសង្គម ក្នុងន័យនេះ គូភាគីនៃកិច្ចសន្យា មានសេរី

[6] មាត្រា ៣ នៃក្រមរដ្ឋប្បវេណី

ភាពពេញលេញក្នុងការជ្រើសរើសភាគីនៃកិច្ចសន្យា របស់ខ្លួននៅពេលដែលខ្លួនចុះកិច្ចស្យា ទោះបីជាកិច្ចសន្យានោះ ជាកិច្ចសន្យាប្រភេទណាក៏ដោយ កុំឱ្យតែកិច្ចសន្យានោះផ្ទុយនិងច្បាប់ ។

តាមក្រមរដ្ឋប្បវេណីមាត្រ ៣៤៥ អ្នកដែលបង្ហាញឆន្ទៈដោយមានវិការៈ អាចលុបកិច្ចសន្យាចោលបាន ។ ការព្រមព្រៀងដែលមានវិការៈ សំដៅទៅលើការព្រមព្រៀងដែលកើតឡើងដោយមាន ការភាន់ច្រឡំ ដោយហិង្សា ឬ ដោយការបន្លំបោកប្រាស់។[7]

## ២.៣ បទប្បញ្ញត្តិតាមការស្ម័គ្រចិត្ត និង បទប្បញ្ញត្តិដោយបង្ខំ

យោងទៅតាមគោលការណ៍ខាងលើ គេពុំដឹងគួរធ្វើដូចម្តេចទេ ក្រៅពីគោរពតាមឆន្ទៈនៃគូភាគី ក្នុងការបដិសេធ មិនអនុវត្តតាមច្បាប់ណាមួយនោះ ក៏ប៉ុន្តែ សូមបញ្ជាក់ថាពុំមែនដូច្នោះទេ។ បើគូភាគីបានកំណត់នូវវិធានអ្វីមួយហើយនោះ វិធាននោះនិងត្រូវយកមកអនុវត្ត ប៉ុន្តែ ចំពោះចំណុចណាដែលមិនបានកំណត់នោះ គេត្រូវយកបទប្បញ្ញត្តិនៃច្បាប់រដ្ឋប្បវេណីមកអនុវត្ត ដើម្បីបំពេញខ្វះចន្លោះ។[8]

ឧទាហរណ៍ នៅក្នុងករណីថាបានកំណត់តម្លៃទំនិញមែន ប៉ុន្តែ ពុំបានសម្រេចថាតើអ្នកណាជាអ្នកត្រូវបង់ថ្លៃឈ្នួលទំនិញ តើគេត្រូវសម្រេចយ៉ាងណា ?

បទប្បញ្ញត្តិ ដែលអនុញ្ញតឱ្យការព្រមព្រៀងរបស់ភាគី មានអាទិភាពជាងសេចក្តីដែលចែងនៅក្នុងមាត្រានៃច្បាប់រដ្ឋប្បវេណីនេះគេហៅថា បញ្ញត្តិតាមការស្ម័គ្រចិត្ត ។

ចំពោះបញ្ញត្តិ ដែលកំណត់ថាទោះជាគូភាគីបានព្រមព្រៀងគ្នាកំណត់យកតាមវិធានយ៉ាងណាក្តី ពុំអាចប្តូសារន័យនៅក្នុងមាត្រានៃច្បាប់បានជាដាច់ខាតទេនោះ គេហៅថា បទប្បញ្ញត្តិដោយបង្ខំ ។

តាមក្រមរដ្ឋប្បវេណីបានចែងអំពីប្រភេទនៃសិទ្ធិប្រត្យក្សជាដើម ដែលជាសិទ្ធិផ្តាច់មុខអនុញ្ញាតឱ្យគេអាចប្រកាសនូវសិទ្ធិគ្រប់គ្រងដាច់ខាត តតាំង និង គ្រប់តតិយជន។

ដូច្នោះយើងម្នាក់ៗមិនអាចចេះតែបង្កើតវិធានណា ដែលខុសពីមាត្រាចែងក្នុងច្បាប់បានតាមចិត្តបានឡើយ (គោលការណ៍កំណត់សិទ្ធិប្រត្យក្សដោយច្បាប់) ។[9]

[7] មាត្រា ៧ ក្រឹត្យ-ច្បាប់លេខ ៣៨

[8] សៀវភៅនិតីកិច្ចពិសេសរៀបរៀងដោយលោក យស បានចំរុង និង លោក ខាំ សុមករា ទំព័រទី៣

[9] មាត្រា ១៣១ ក្រមរដ្ឋប្បវេណី

# ជំពូកទី២
# ការបង្កើតកិច្ចសន្យា

## ផ្នែកទី១៖ គោលការណ៍នៃការបង្កើតកិច្ចសន្យា

កិច្ចសន្យា គឺជាកិរិយាដែលបុគ្គលពីរនាក់ ឬច្រើននាក់មានឆន្ទៈត្រូវគ្នាព្រមបង្កើត កែប្រែ ឬរំលត់នូវកាតព្វកិច្ច។[10] ក្នុងន័យនេះ កិច្ចសន្យាគឺជាការត្រូវគ្នានៃឆន្ទៈដែលចង់បង្កើតកែប្រែ ឬរំលត់កាតព្វកិច្ច។ កិច្ចសន្យាដែលបង្កើតឡើងត្រូវតែបម្រើឱ្យផលប្រយោជន៍បុគ្គល និងផលប្រយោជន៍សង្គម ហើយភាគីនៃកិច្ចសន្យា ត្រូវអនុវត្តន៍កិច្ចសន្យា ដោយភាពស្មោះត្រង់ និងសីលធម៌សង្គម។

យោងតាមមាត្រា ៣៣៦ កថាខណ្ឌទី១ កិច្ចសន្យាមានអានុភាពដោយសារសំណើ និងស្វីការត្រូវគ្នា ។ [11] ទន្ទឹមនឹងនេះ កិច្ចសន្យាត្រូវបានបង្កើតឡើងនៅពេលដែលអំពីស្វីការបានដល់អ្នកស្នើ។

### ១.១ សំណើ

សំណើ[12] គឺជាការសុំបង្កើតកិច្ចសន្យា ដែលធ្វើឡើងដោយមានឆន្ទៈភ្ជាប់ខ្លួនជាមួយនឹងចំណងគតិយុត្ត ក្នុងករណីដែលមានស្វីការរបស់ភាគីម្ខាងទៀត ចំពោះសំណើនេះ។ សំណើ ត្រូវមានអានុភាព នៅពេលសំណើនោះបានដល់ភាគីម្ខាងទៀត។

ពាក្យថា បានដល់មានន័យថា ឧទាហរណ៍ ដូចជា វាមិនមានភាពចាំបាច់ដែលអ្នកទទួលសំណើបានទទួល ឬបានបើកអានសំណើនោះទេ គឺអោយតែបានទៅបានដល់។ ឧទាហរណ៍ អ្នករស់នៅជាមួយនឹងអ្នកទទួលសំណើបានទទួលឬសំណើបានទៅដល់ប្រអប់សំបុត្រនៃផ្ទះអ្នកទទួលសំណើ(ភាគីម្ខាងទៀត)។

#### ១.១.១ លក្ខខណ្ឌនៃសំណើ

##### ១.១.១.១ គោលបំណងពិតប្រាកដ

ត្រូវកំណត់តាមពាក្យសំដី ឬអំពើរបស់ភាគី ដែលជាមនុស្សប្រកបដោយគតិដោយសម្រេចមានហេតុផលត្រឹមត្រូវ។ ប្រសិនបើ អ្នកស្នើធ្វើសំណើដោយការភ័យខ្លាច ខឹង លេងសើចបញ្ចើចបញ្ចើ ញុះញង់ សំណើបែបនេះ គឺគ្មានគោលបំណងច្បាស់លាស់ទេ ដែលជាហេតុមិនអាចចាត់ទុកជាសំណើមានប្រសិទ្ធភាពនោះទេ។[13]

##### ១.១.១.២ ភាពច្បាស់លាស់នៃសំណើ

សំណើត្រូវតែមានខ្លឹមសារជាក់លាក់ ច្បាស់លាស់និងសមហេតុផលនេះមានន័យថា សំណើត្រូវតែបញ្ជាក់ឱ្យបានច្បាស់លាស់អំពីប្រភេទនៃវត្ថុបរិមាណតម្លៃគុណភាពពេលវេលាទីកន្លែងជាដើម។[14]

---

[10]មាត្រា ៣១១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[11] មាត្រា ៣៣៦ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[12] មាត្រា ៣៣៧ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[13] ច្បាប់កិច្ចសន្យា មេធាវី ជ្រា ឈុនឡេង ទំព័រ ៤ ឆ្នាំ ២០១៨

[14] ច្បាប់កិច្ចសន្យា មេធាវី ជ្រា ឈុនឡេង ទំព័រ ៥ ឆ្នាំ ២០១៨

#### ១.១.១.៣ ការជូនដំណឹងអំពីសំណើ

សំណើ[15] ត្រូវមានអានុភាពនៅពេលដែលសំណើនោះបានដល់ភាគីម្ខាងទៀតដូច្នេះអ្នកធ្វើសំណើត្រូវតែបញ្ជូនសំណើ ឱ្យដល់អ្នកទទួលសំណើ តាមគ្រប់មធ្យោបាយ ដែលអ្នកធ្វើសំណើអាចធ្វើទៅបាន។ នៅពេលដែលអ្នកទទួលសំណើមិនបានទទួលសំណើទេ នោះអ្នកទទួលសំណើក៏គ្មានសិទ្ធិដើម្បីធ្វើស្វីការតបនឹង សំណើនោះដែរ នេះមានន័យថាគ្មានកិច្ចសន្យារវាងអ្នកធ្វើសំណើ និងអ្នកទទួលសំណើទេ។

## ១.២ ស្វីការ

ស្វីការ គឺជាការបង្ហាញឆន្ទៈដែលអ្នកទទួលសំណើយល់ព្រមចំពោះសំណើនោះ។ មានន័យថាជាការឆ្លើយតបយល់ព្រមទៅនឹងសំណើក្នុងគោលបំណងដើម្បីបង្កើតកិច្ចសន្យា។ ស្វីការ ត្រូវមានអានុភាពនៅពេលដែលស្វីការនោះបានដល់អ្នកស្នើ។ ប៉ុន្តែប្រសិនបើដំណឹងអំពីការដកស្វីការវិញដល់អ្នកស្នើនៅពេលព្រមគ្នានឹងពេលស្វីការដល់ ឬមុនពេលស្វីការដល់នោះអានុភាពនៃស្វីការ មិនត្រូវកើតឡើយ។

### ១.២.១ លក្ខខណ្ឌស្វីការ

#### ១.២.១.១ ស្វីការត្រូវតែឡើងដោយអ្នកទទួលសំណើ

មានតែអ្នកទទួលសំណើតែប៉ុណ្ណោះ ទើបអាចធ្វើស្វីការចំពោះសំណើនោះក្នុងគោលបំណងបង្កើតកិច្ចសន្យាមួយបាន។ លើកលែងតែការតំណាង ឬជនដែលត្រូវបានកម្រិតសមត្ថភាព។[16]

#### ១.២.១.២ ការជូនដំណឹងអំពីស្វីការ

ស្វីការ[17] ត្រូវមានអានុភាពនៅពេលដែលស្វីការនោះបានដល់អ្នកស្នើ។ កិច្ចសន្យាកើតឡើងនៅពេលដែលសំណើជួបនឹងស្វីការ។ ដូច្នេះប្រសិនបើអ្នកទទួលសំណើចង់បង្កើតកិច្ចសន្យា នោះគាត់ត្រូវធ្វើយ៉ាងណាបញ្ជូនស្វីការរបស់គាត់ឱ្យបានទៅដល់ភាគីអ្នកធ្វើសំណើ។

#### ១.២.១.៣ ស្វីការត្រូវតែធ្វើមុនពេលសំណើរំលត់

ប្រសិនបើ សំណើត្រូវបានគេរំលត់មុនពេលស្វីការកើតឡើងនោះគ្មានកិច្ចសន្យាដែលមានសុពលភាពកើតឡើងទេ ដោយហេតុថាកិច្ចសន្យាដែលមាន សុពលភាពត្រូវកើតឡើងដោយសារ ការជួបគ្នារវាងសំណើដែលមានសុពលភាព និងស្វីការដែលមានសុពលភាព។ ប្រសិនបើគូរភាគីកំពុងតែនិយាយទល់មុខគ្នានោះនឹងមានភាពងាយស្រួលកំណត់ថា ពេលណាសំណើនឹងត្រូវរំលត់តែប្រសិនបើភាគីបានធ្វើទំនាក់ទំនងជាមួយគ្នាពីចម្ងាយនោះវានឹងមានភាពពិបាកក្នុងការកំណត់ ថាពេលណាសំណើនឹងត្រូវរំលត់។

អ្នកស្នើ[18] អាចចាត់ទុកថាស្វីការដែលបានមកដល់អ្នកស្នើក្រោយពេលផុតអំឡុងពេលសម្រាប់ស្វីការជាសំណើថ្មី។

---

[15] មាត្រា ៣៣៧ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[16] ច្បាប់កិច្ចសន្យា មេធាវី ជ្រា ឈុនឡេង ទំព័រ ១៣ ឆ្នាំ ២០១៨

[17] មាត្រា ៣៣៧ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[18] មាត្រា ៣៤១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

### ១.៣ សមត្ថភាពនៃភាគី

សកម្មភាពដែលភាគីបានធ្វើក្នុងស្ថានភាពដែលខ្លួនមិនអាចយល់ដឹងនិងវិនិច្ឆ័យបានអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួនអាចលុបចោលបាន។[19]

មានន័យថា ភាគីទាំងអស់នៃកិច្ចសន្យាត្រូវមានលក្ខណៈ និងសមត្ថភាពស្របច្បាប់ទើបអាចបង្កើតកិច្ចសន្យាជាមួយគ្នាបាន។ សមត្ថភាពគឺនិយាយអំពីកត្តាដូចខាងក្រោម៖

-ជនទាំងឡាយដែលមានអាយុគ្រប់១៨ ឆ្នាំ អាចធ្វើកិច្ចសន្យាបានគ្រប់ពេលវេលា។[20]

-បញ្ញាញាណគ្រប់គ្រាន់៖ ភាគីដែលមានអាយុ ១៨ ឆ្នាំ ទោះបីភាគីដែលមានអាយុ ៥០ ឆ្នាំក៏ដោយ ប៉ុន្តែគ្មានបញ្ញាញាណគ្រប់គ្រាន់ ក៏មិនអាចធ្វើកិច្ចសន្យាឲ្យមានសុពលភាពបានដែរ។

-មានជាតិស្រវឹង៖ ភាគីដែលមានជាតិស្រវឹងក្នុងខ្លួន (ស្រា គ្រឿងញៀន) ធ្វើឲ្យសាមីខ្លួនបាត់បង់បញ្ញាញាណក៏មិនអាចធ្វើកិច្ចសន្យាមានសុពលភាពដែរ។ ក្នុងករណីដែលបុគ្គលណាមានលក្ខណៈខាងលើ ហើយបានធ្វើកិច្ចសន្យាទាំងនោះអាចទុកជាមោឃៈបានបើបុគ្គលរបៀបនេះទាមទារ សូមឲ្យកិច្ចសន្យាដែលបានគេធ្វើរួចហើយនោះកិច្ចសន្យាទុកជាមោឃៈ។

### ១.៤ លក្ខខណ្ឌទម្រង់នៃកិច្ចសន្យា

កិច្ចសន្យាអាចធ្វើបានដោយផ្ទាល់មាត់ ឬជាលាយល័ក្ខអក្សរ។[21] ប៉ុន្តែដើម្បីជៀសវាងការឈ្លោះប្រកែកគ្នាជារឿយៗអំពីកិច្ចសន្យាដែលធ្វើដោយផ្ទាល់មាត់ដែលគ្មានភស្តុតាងច្បាស់លាស់ ទើបច្បាប់តម្រូវឲ្យមានកិច្ចសន្យាទាំងអស់ដែលមានសារៈសំខាន់ត្រូវធ្វើជាលាយល័ក្ខអក្សរ។

កិច្ចសន្យាដែលច្បាប់តម្រូវឲ្យធ្វើជាលាយល័ក្ខអក្សរមាន៖

កិច្ចសន្យាដែលពាក់ព័ន្ធនឹងដីធ្លី ឬអចលនវត្ថុដូចជា ការជួលផ្ទះ ឬ លក់ដីជាដើមកិច្ចសន្យាណាដែលមិនអាចអនុវត្តសម្រេចបានក្នុងរយៈពេល១ឆ្នាំ ចាប់ពីពេលដែលកិច្ចសន្យានេះបានកើតឡើងកិច្ចសន្យាធានាសងបំណុលជំនួសរបស់អ្នកធានាជាភាគីទីបី ដែលជាកិច្ចសន្យាភ្ជាប់របស់ម្ចាស់ប្រាក់និងអ្នកធានាកិច្ចសន្យាដែលមានតម្លៃលើសពី ៥០០០ រៀលឡើងទៅ។

សម្គាល់៖ កិច្ចសន្យាមិនអាចបង្ខំឲ្យអនុវត្តបានជាកិច្ចសន្យាមួយដែលមានសុពលភាពពេលបង្កើតដំបូងតែក្រោយមកមិនអាចបង្ខំឲ្យអនុវត្តបានព្រោះមានការការពារតាមផ្លូវច្បាប់។

ឧទាហរណ៍៖ នាងបានទិញទូរស្សន៍ពីហាងមួយដោយធ្វើកិច្ចសន្យាបង់រំលោះចំនួនប្រាំខែនាងបង់ប្រាក់កម្ចីពីរខែស្រាប់តែអត់ការងារធ្វើហើយដាក់ពាក្យប្រកាសធនក្ស័យនៅតុលាការប្រកាសធនក្ស័យឲ្យ នាង ដូច្នេះមិនអាចទារប្រាក់បំណុលពីនាងបានទេ។

---

[19] មាត្រា ១៤ នៃក្រមរដ្ឋប្បវេណី

[20] មាត្រា ១៤ នៃក្រឹត-ច្បាប់លេខ៣៨

[21] មាត្រា ១៤ នៃក្រឹត-ច្បាប់លេខ៣៨

### ១.៥ ចំណាត់ថ្នាក់នៃកិច្ចសន្យា

#### ១.៥.១ កិច្ចសន្យាដែលយកតម្លៃថ្នូរ

ភាគីទាំងពីរមានកាតព្វកិច្ចផ្តល់នូវកម្រៃទៅវិញទៅមកដែលមានតម្លៃស្មើគ្នា។[22] ឧទាហរណ៍៖ កិច្ចសន្យាលក់ទិញភាគីអ្នកកាតព្វកិច្ចប្រគល់វត្ថុ រីឯអ្នកទិញ មានកាតព្វកិច្ចប្រគល់ប្រាក់។

#### ១.៥.២ កិច្ចសន្យាដែលមិនយកតម្លៃថ្នូរ

កិច្ចសន្យានេះ មានន័យថាមានតែភាគីម្ខាងផ្តល់នូវកម្រៃចំណែកឯភាគីម្ខាងទៀត មិនមានកាតព្វកិច្ច ឬមានបន្ទុកដែលមិនសមមូល។ ឧទាហរណ៍៖ ដ៏សាមញ្ញនៃកិច្ចសន្យានេះ គឺភាគច្រើនជាប្រទានកម្ម។ ទាក់ទងនឹងកិច្ចសន្យាដែលមិនយកតម្លៃថ្នូរ នៅក្នុងករណីនៃប្រទានកម្មគឺវាមានលក្ខណៈបន្ធូរបន្ថយចំពោះកាតព្វកិច្ចរបស់ទាយក។ វាមានន័យថា ជាគោលការណ៍ទាយកមិនចាំបាច់ទទួលខុសត្រូវចំពោះវិការៈដែលបានកើតមានឡើងដោយសារកិច្ចសន្យានេះទេ។[23]

#### ១.៥.៣ កិច្ចសន្យាទ្វេភាគី

ភាគីទាំងពីរមានកាតព្វកិច្ចអនុវត្តកិច្ចសន្យាដែលមានតម្លៃសមមូលគ្នា។ ឧទាហរណ៍៖ សារ៉ាបានផ្ញើរពាក្យសន្យាមួយទៅឲ្យមិត្តភក្តិម្នាក់ឈ្មោះ កញ្ញា ថានឹងលក់ផ្ទះឲ្យទៅឈ្មោះ កញ្ញា ក្នុងតម្លៃ ៤០០០០$USD (បួនម៉ឺនដុល្លារអាមេរិក)។ ឈ្មោះ កញ្ញា ផ្ញើពាក្យសន្យាប្រាប់ សារ៉ា ថាខ្លួនយល់ព្រមទិញ។

#### ១.៥.៤ កិច្ចសន្យាឯកតោភាគី

មានតែភាគីម្ខាងមានកាតព្វកិច្ចចំណែកភាគីម្ខាងមិនមានកាតព្វកិច្ច ឬគ្រាន់តែមានបន្ទុកតែមានតម្លៃមិនសមមូល។ ប្រសិនបើភាគីម្ខាងទៀតមានបន្ទុក ប៉ុន្តែមានតម្លៃមិនសមមូលក្រមរដ្ឋប្បវេណី បានចែងនូវមាត្រាដែលមានលក្ខណៈស្រដៀងគ្នាទៅនឹងកិច្ចសន្យាទ្វេភាគីដែរ ដូចជាការទទួលខុសត្រូវក្នុងការធានារបស់អ្នកលក់ការតវ៉ាអោយអនុវត្តព្រមគ្នា ការរំលាយកិច្ចសន្យា។[24] ឧទាហរណ៍ លោកសីហា បានដាក់ចុះផ្សាយក្នុងកាសែតថា លោកនឹងផ្តល់រង្វាន់ជាទឹកប្រាក់ចំនួន១លានដុល្លារដល់ កុម្ភៈ ក្នុងការដែលបានរករបកគំហើញថ្មីផ្នែកទីផ្សារដើម្បីអភិវឌ្ឍក្រុមហ៊ុមឲ្យបានរីកចម្រើនឈានដល់កម្រិតកំពូល។

## ផ្នែកទី២៖ លក្ខខណ្ឌដើម្បីបង្កើតអានុភាពនៃកិច្ចសន្យា

### ២.១. លក្ខខណ្ឌសុពលភាពនៃកិច្ចសន្យា

កិច្ចសន្យា មានអនុភាពនៅពេលដែលសំណើ និងស្វីការត្រូវគ្នា។[25] ប៉ុន្តែនៅក្នុងករណីដែលការបង្ហាញឆន្ទៈមានវិការៈ ឬខ្លឹមសារនៃសកម្មភាព[26] នេះផ្ទុយនឹងច្បាប់ ឬភាពមិនត្រឹមត្រូវនៅក្នុងសង្គម នោះអនុភាពនឹងត្រូវបានបដិសេធដោយក្រមរដ្ឋប្បវេណី។ ដូច្នេះដើម្បីឱ្យកិច្ចសន្យាមួយមានសុពលភាពកិច្ចសន្យានោះត្រូវបំពេញ

---

[22] កិច្ចសន្យាពិសេស (លោកសាស្ត្រាចារ្យ ឆាយ ហុង) ទំព័រ៥

[23] មាត្រា ៥៧៤ នៃក្រមរដ្ឋប្បវេណី ២០០៧

[24] មាត្រា ៥៧៤ កថាខណ្ឌទី២.៣ និង៥ នៃក្រមរដ្ឋប្បវេណី

[25] មាត្រា ៣៣៦ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី

[26] ពាក្យ សកម្មភាព នៅទីនេះសំដៅលើកិច្ចសន្យា ឫសកម្មភាពឯកតោភាគី

ឱ្យបាននូវលក្ខខណ្ឌចាំបាច់ គឺសំណើ និងស្ទីការត្រូវគ្នា និងលក្ខខណ្ឌគ្រប់គ្រាន់ គឺមានលក្ខខណ្ឌទូទៅទាក់ទងនឹងភាគីដែលរួមមានសមត្ថភាពទទួលសិទ្ធិ សមត្ថភាពខាងឆន្ទៈ សមត្ថភាពក្នុងការធ្វើសកម្មភាព និងគ្មានវិការៈក្នុងការបង្ហាញឆន្ទៈ និង លក្ខខណ្ឌទូទៅទាក់ទងនឹងខ្លឹមសារនៃកិច្ចសន្យាដែលរួមមាន ភាពច្បាស់លាស់ ភាពស្របច្បាប់ ភាពសមស្របតាមស្ថានភាពសង្គម និងភាពគ្មានការបង្ហាញឆន្ទៈមិនពិត។

### ២.១.១. លក្ខខណ្ឌទូទៅទាក់ទងនឹងភាគី

លក្ខខណ្ឌទូទៅទាក់ទងនឹងភាគីដើម្បីឱ្យកិច្ចសន្យាមានសុពលភាព គឺភាគីត្រូវមានសមត្ថភាពទទួលសិទ្ធិត្រូវមានសមត្ថភាពខាងឆន្ទៈត្រូវមានសមត្ថភាពក្នុងការធ្វើសកម្មភាព និងគ្មានវិការៈក្នុងការបង្ហាញឆន្ទៈ។[27] ការកម្រិតលក្ខខណ្ឌបែបនេះក្នុងគោលបំណងដើម្បីការពារ កុំឱ្យមានការខូចខាតដល់កិច្ចការជំនួញរបស់ជនទាំងឡាយដែលខ្វះសមត្ថភាពដូចបានកំណត់ខាងលើ។

**ក.** ភាគីត្រូវមានសមត្ថភាពទទួលសិទ្ធិ

សំដៅទៅលើស្ថានភាពជាក់លាក់របស់រូបវន្តបុគ្គលម្នាក់ដែលជាភាគីក្នុងការទទួលបាននូវសិទ្ធិ ដូចជា សិទ្ធិក្នុងការបង្កើតកិច្ចសន្យាសិទ្ធិទទួលបានមរតកសិទ្ធិទាមទារសំណងខូចខាតជាដើម។ ជាគោលការណ៍រូបវន្តបុគ្គលគ្រប់រូប មានសមត្ថភាពទទួលបាននូវសិទ្ធិបុគ្គលដូចៗគ្នា មិនថាជាជនជាតិខ្មែរ ឬបរទេសឡើយ។ ប៉ុន្តែ ជនជាតិបរទេសមិនអាចទទួលបាន ឬកាន់កាប់នូវសិទ្ធិមួយចំនួន ដែលត្រូវបានកំណត់ឡើយ ក្នុងករណីមានបញ្ញត្តិផ្សេងនៅក្នុងច្បាប់ ឬសន្ធិសញ្ញាអនុសញ្ញាអន្តរជាតិ។[28] ជាក់ស្ដែងនៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ៤៤ កថាខណ្ឌទី១បានចែងថា "មានតែរូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានសញ្ជាតិខ្មែរទេទើបមានសិទ្ធិជាម្ចាស់កម្មសិទ្ធិលើដីធ្លី"។

**ខ.** ភាគីត្រូវមានសមត្ថភាពខាងឆន្ទៈ

សំដៅទៅលើភាគីដែលមានសមត្ថភាពអាចយល់ដឹង និងវិនិច្ឆ័យបានអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួនបើមិនដូច្នោះទេសកម្មភាពនោះអាចនឹងត្រូវលុបចោលបាន។[29]

**គ.** ភាគីត្រូវមានសមត្ថភាពក្នុងការធ្វើសកម្មភាព

សំដៅទៅលើជនក្រៅពីជនដែលត្រូវបានកម្រិតសមត្ថភាពធ្វើសកម្មភាព ដូចដែលបានកំណត់នៅក្នុងមាត្រា ១៦ នៃក្រមរដ្ឋប្បវេណី។ ជនដែលត្រូវបានកម្រិតសមត្ថភាពមានបីប្រភេទគឺអនីតិជន ជននៅក្រោមអាណាព្យាបាលទូទៅ និងជននៅក្រោមហិតូបត្ថម្ភ។ កិច្ចសន្យាដែលបង្កើតឡើងដោយជនក្រៅពីជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាព គឺមានសុពលភាពពេញលេញប្រសិនបើពុំមានមូលហេតុផ្សេងទៀតដែលនាំឱ្យមោឃៈ ឬមូលហេតុដែលអាចលុបចោលកិច្ចសន្យាបាន។

**ឃ.** ភាគីគ្មានវិការៈក្នុងការបង្ហាញឆន្ទៈ

---

[27] អត្ថបទស្ដីពីលក្ខខណ្ឌសុពលភាព និងការរំលាយកិច្ចសន្យា ទំព័រ១

[28] មាត្រា ៧ ក្រមរដ្ឋប្បវេណី

[29] មាត្រា ១៤ ក្រមរដ្ឋប្បវេណី

ភាពគ្មានវិការៈក្នុងការបង្ហាញឆន្ទៈ[30] សំដៅទៅលើការបង្ហាញឆន្ទៈដែលមានសុពលភាព ដែលជាលក្ខខណ្ឌដើម្បីឱ្យកិច្ចសន្យាមានអនុភាពចងភាគីទាំងពីរ។ ក្នុងករណីដែលកាបង្ហាញឆន្ទៈត្រូវបានធ្វើឡើងដោយការភាន់ច្រឡំដោយការឆបោក ឬការគម្រាមកំហែង ឬការបង្ហាញឆន្ទៈមិនពិតរបស់ភាគីម្ខាងទៀត និងដោយអំពើឆ្លៀតឱកាសដោយមាន គោលបំណងកេងយកចំណេញហួសហេតុនោះគេហៅថា ការបង្ហាញឆន្ទៈដែលមានវិការៈ។ ក្នុងករណីបែបនេះកិច្ចសន្យាអាចត្រូវបានលុបចោលដោយសារមានវិការៈក្នុងការបង្ហាញឆន្ទៈ។

### ២.១.២. លក្ខខណ្ឌទូទៅទាក់ទងនឹងខ្លឹមសារនៃកិច្ចសន្យា

ខ្លឹមសារនៃកិច្ចសន្យា គឺជាលក្ខខណ្ឌមួយទៀត ដើម្បីធ្វើឱ្យកិច្ចសន្យាមួយមានសុពលភាពពេញលេញ។ លក្ខខណ្ឌទូទៅទាក់ទងនឹងខ្លឹមសារនៃកិច្ចសន្យា មាន៤ ដូចខាងក្រោម៖

**ក.** ភាពច្បាស់លាស់

ប្រសិនបើកិច្ចសន្យាមានភាពមិនច្បាស់លាស់វានឹងនាំឱ្យមោឃៈព្រោះខ្លឹមសារនៃកាតព្វកិច្ចក្នុងកិច្ចសន្យាមិនអាចយកទៅអនុវត្តបានតាមរយៈតុលាការ។[31]

ឧទាហរណ៍៖ លោក A បានសន្យាថាបើ B អាយុ១៨ឆ្នាំ លោក A នឹងឱ្យអ្វីៗដែលល្អដល់ B ។ ចំពោះខ្លឹមសារនៃការសន្យាបែបនេះ៖ តុលាការមិនអាចចេញសាលក្រម ឬមិនអាចអនុវត្តកាតព្វកិច្ចដោយបង្ខំបានទេ ដោយហេតុថា ខ្លឹមសារនៃកិច្ចសន្យាមានភាពមិនច្បាស់លាស់។ ក៏ប៉ុន្តែ វាមិនមានភាពចាំបាច់ទេក្នុងការសម្រេចថារាល់ខ្លឹមសារទាំងអស់នៅក្នុងកិច្ចសន្យាត្រូវតែមានភាពច្បាស់លាស់។ វាគឺមានលក្ខណៈគ្រប់គ្រាន់ដែលបង្ហាញពីភាពច្បាស់លាស់ ប្រសិនបើផ្នែកសំខាន់នៃកិច្ចសន្យាអាចត្រូវបានបង្ហាញឱ្យឃើញច្បាស់តាមរយៈការបកស្រាយ។ ដូច្នេះភាពច្បាស់លាស់នៅទីនេះគឺសំដៅត្រឹមតែផ្នែកសំខាន់នៃកិច្ចសន្យាតែប៉ុណ្ណោះ។

**ខ.** ភាពស្របច្បាប់

ប្រសិនបើខ្លឹមសារនៃកិច្ចសន្យាផ្ទុយនឹងបញ្ញត្តិដែលអនុវត្តដោយបង្ខំណាមួយ នោះវាត្រូវបានចាត់ទុកជាមោឃៈ។[32] បញ្ញត្តិដែលអនុវត្តដោយបង្ខំគឺ សំដៅទៅលើបញ្ញត្តិដែលបដិសេធរាល់អានុភាពនៃសកម្មភាពគតិយុត្ត ដែលបានធ្វើឡើងផ្ទុយនឹងបញ្ញត្តិនេះ។

ឧទាហរណ៍៖ នៅក្នុងករណីដែលគូភាគីបានព្រមព្រៀងគ្នាថា "ភាគីម្ខាងមិនអាចលុបចោលកិច្ចសន្យាបានទេ ទោះបីជាគាត់បានបង្ហាញឆន្ទៈដោយសារការគំរាមកំហែងក៏ដោយ"ការព្រមព្រៀងបែបនេះត្រូវបានចាត់ទុកជាមោឃៈព្រោះផ្ទុយនឹងបញ្ញត្តិការអនុវត្តដោយបង្ខំ។

**គ.** ភាពសមស្របតាមស្ថានភាពសង្គម

លក្ខខណ្ឌនេះសំដៅទៅលើភាពមិនផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និងទំនៀមទម្លាប់ល្អរបស់សង្គម។[33] មានន័យថាទោះបីជាគូភាគីបង្ហាញឆន្ទៈដោយគ្មានវិការៈក៏ដោយកិច្ចសន្យាត្រូវបានចាត់ទុកជាមោឃៈដែរប្រសិនបើខ្លឹមសារនៃកិច្ចសន្យាផ្ទុយពីស្ថានភាពសង្គម និងទំនៀមទម្លាប់ល្អ។

---

30 សូមមើលផ្នែកទី២ វិការៈក្នុងការបង្ហាញឆន្ទៈ និងសុពលភាពនៃកិច្ចសន្យា មាត្រា ៣៤៥ ដល់មាត្រា ៣៥៤ នៃក្រមរដ្ឋប្បវេណី

31 អត្ថបទស្តីពីលក្ខខណ្ឌសុពលភាព និងការរំលាយកិច្ចសន្យា ទំព័រ២

32 មាត្រា ៣៥៤ កថាខណ្ឌទី១ ចំណុច ក នៃក្រមរដ្ឋប្បវេណី

33 មាត្រា ៣៥៤ កថាខណ្ឌទី១ ចំណុច ខ នៃក្រមរដ្ឋប្បវេណី

ឃ. គ្មានការបង្ហាញឆន្ទៈមិនពិត

លក្ខខណ្ឌនេះសំដៅថា កិច្ចសន្យាអាចមានសុពលភាពបានលុះត្រាតែគ្មានការបង្ហាញឆន្ទៈមិនពិត។ មានន័យថាបើកិច្ចសន្យាធ្វើឡើងដោយមានការឃុបឃិតជាមួយភាគីម្ខាងទៀតត្រូវចាត់ទុកជាមោឃៈ។[34]

ឧទាហរណ៍៖ លោក ក លក់ដីទៅលោក ខ ដោយឃុបឃិតគ្នានៅក្នុងគោលបំណងបញ្ចៀសនូវការរឹបអូសពីម្ចាស់បំណុល។ បន្ទាប់មកលោក ក បានផ្ទេរការចុះបញ្ជីនៃដីទៅឱ្យលោក ខ។ នេះគឺជាការបង្ហាញឆន្ទៈមិនពិតដូច្នេះកិច្ចសន្យារវាងលោក ក និងលោក ខ ត្រូវបានចាត់ទុកជាមោឃៈ។

## ២.២ អានុភាពនៃកិច្ចសន្យា

### ២.២.១ អានុភាពជាចំណង និងអានុភាពដោយធៀប

ជាបឋមដោយផ្អែកលើមូលដ្ឋាននៃការព្រមព្រៀងគ្នា រវាងភាគីទាំងសងខាងអានុភាពនៃកិច្ចសន្យាបង្កើតឱ្យមានចំណងកាតព្វកិច្ចរវាងភាគី (ត្រូវតែអានុវត្តតាមកិច្ចសន្យា) ។[35] ដូច្នេះនៅពេលដែលភាគីម្ខាងមិនអានុវត្តតាមកិច្ចសន្យាភាគីម្ខាងទៀតអាចប្តឹងទៅតុលាការបង្ខំឱ្យអនុវត្តតាម ឬមួយក៏តម្រូវឱ្យបង់សំណងចំពោះការខូចខាតជំនួសឱ្យការធ្វើសកម្មភាពដែលបានសន្យាពីដំបូងទី (លើកលែងតែនៅក្នុងកិច្ចសន្យានោះ ភាគីទាំងសងខាងបានព្រមព្រៀងគ្នាជាពិសេសថាគ្មានការបង្ខិតបង្ខំឱ្យអនុវត្តតាមទេនោះ)។ ម្យ៉ាងទៀតជាគោលការណ៍អានុភាពនៃកិច្ចសន្យាគឺជាអានុភាពដោយធៀបដែលចងតែភាគីក្នុងកិច្ចសន្យាតែប៉ុណ្ណោះ។

ឧទាហរណ៍៖ដូចជាគេអាចធ្វើកិច្ចសន្យាដោយផ្តល់ផលប្រយោជន៍ទៅជនទី ៣ បាន នៅក្នុងការលក់ទិញរវាងឈ្មោះ A និង ឈ្មោះ B ជាដើម ដោយមានបន្ថែមការព្រមព្រៀងគ្នាថា ប្រាក់ថ្លៃទំនិញនោះត្រូវបង់ផ្ទាល់ទៅជនទី៣ ឈ្មោះ C (កិច្ចសន្យាដែលធ្វើឡើងសម្រាប់តតិយជននឹងមានអធិប្បាយនៅខាងក្រោយ។ ចាប់ពីមាត្រា ៥៣៧ តទៅក៏ប៉ុន្តែនេះមិនមែនមានន័យថាជាការព្រមព្រៀងគ្នាដាក់ករណីយកិច្ចលើជនទី៣នោះឡើយ ។

### ២.២.២ សិទ្ធិតវ៉ាឱ្យអនុវត្តព្រមគ្នា

ជាងនេះទៅទៀត ចំពោះកិច្ចសន្យាឧបតោភាគីច្បាប់បានកំណត់ឱ្យមានសិទ្ធិតវ៉ាឱ្យអនុវត្តព្រមគ្នាដោយផ្អែកលើអានុភាពនៃវត្តមានរបស់កិច្ចសន្យា។[36] ឧទាហរណ៍៖ ដូចជាក្នុងការទិញលក់ជាដើមអ្នកទិញអាចតវ៉ា (ធ្វើការអះអាងតទល់នឹងការទាមទាររបស់ភាគីម្ខាងទៀត) ថាលុះណាតែអ្នកលក់ប្រគល់ទំនិញឱ្យខ្លួនទើបខ្លួនព្រមបង់ថ្លៃឱ្យ។ ហើយផ្ទុយទៅវិញអ្នកលក់អាចតវ៉ាបានថាលុះណាតែអ្នកទិញបង់ថ្លៃឱ្យខ្លួនទើបខ្លួនប្រគល់ទំនិញឱ្យ មាត្រា ៥៣៣ ។ ការតវ៉ានេះអាចអនុវត្តបានរហូតដល់ពេលដែលភាគីម្ខាងទៀតបានផ្តល់ការអនុវត្តកាតព្វកិច្ចរបស់គេ ពោលគឺជាការបង់ថ្លៃជាដើម) ។

ដូច្នេះសិទ្ធិតវ៉ាឱ្យអនុវត្តគ្នានៃភាគីទាំងសងខាងនេះ ជាការជំរុញឱ្យមានការអនុវត្តកាតព្វកិច្ចរបស់គ្នាទៅវិញទៅមកហើយជាលទ្ធផលចុងក្រោយធ្វើឱ្យមានការផ្តល់តាវកាលិកទៅវិញទៅមកបាន។ ជាធម្មតាទេ ប្រសិនបើភាគីទាំងសងខាងបានកំណត់ជាមួយគ្នាដោយមូលហេតុណាមួយនោះថានឹងបង់ប្រាក់ជាមុន នោះ

[34] មាត្រា ៣៥៣ នៃក្រមរដ្ឋប្បវេណី

[35] ច្បាប់ស្តីពីសិទ្ធលើបំណុល (ជំពូកទី៤)

[36] ច្បាប់ស្តីពីសិទ្ធលើបំណុល (ជំពូកទី៤)

ត្រូវក្លាយទៅជាវិធានដែលភាគីទាំងសងខាងបានព្រមព្រៀងគ្នា ហើយគេមិនអាចប្រើសិទ្ធិតវ៉ាឱ្យអនុវត្តព្រមគ្នាបានទេ ។

### ២.៣ អានុភាពនៃកិច្ចសន្យាចំពោះភាគី

ការកកើតកិច្ចសន្យាមួយឡើង វាបានបង្កើតឱ្យមាននូវអានុភាពនៃចំណង ដែលចងភ្ជាប់ទំនាក់ទំនងគតិយុត្តរវាងភាគីនៃកិច្ចសន្យា។ ហើយនៅក្នុងទំនាក់ទំនងគតិយុត្តនៃកិច្ចសន្យានោះ វាក៏បានបង្កប់នូវសិទ្ធិ និងករណីកិច្ចមួយចំនួនចំពោះគូភាគីផងដែរ។ ជាក់ស្តែងក្នុងមាត្រា ២២ នៃក្រឹត្យ ច្បាប់លេខ ៣៨ ក៏បានបញ្ជាក់ពីអានុភាពនៃកិច្ចសន្យាថាកិច្ចសន្យាមួយអាចមានអានុភាពតែទៅលើភាគីនៃកិច្ចសន្យាប៉ុណ្ណោះ។[37] ផ្ទុយទៅវិញក្នុងក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ មិនបានកំណត់យ៉ាងដូច្នេះទេ កិច្ចសន្យាក៏អាចមានអានុភាពចំពោះតតិយជនផងដែរ ។ អានុភាពនៃកិច្ចសន្យា សំដៅទៅលើការបង្កឱ្យមានផលវិបាកគតិយុត្តដែលកើតចេញពីកិច្ចសន្យាមួយដូចជាការបង្កើតឱ្យមានសិទ្ធិ និងករណីកិច្ចជាដើម។ ហើយភាគីដែលមានសិទ្ធិ និងករណីកិច្ចនោះ គឺមានម្ចាស់បំណុល និងកូនបំណុលដែលទទួលបានឋានៈពីកិច្ចសន្យា។ រាល់សិទ្ធិ និងករណីកិច្ចរបស់ភាគីក្នុងកិច្ចសន្យាវាគឺមានភាពខុសៗគ្នាអាស្រ័យទៅតាមប្រភេទនៃកិច្ចសន្យានីមួយៗ។ ជាក់ស្តែងយើងលើកយកប្រភេទកិច្ចសន្យា២ធំៗគឺ កិច្ចសន្យាអញ្ញមញ្ញនិង កិច្ចសន្យាឯកតោភាគី ។ កិច្ចសន្យាដែលភាគីមានកាតព្វកិច្ចចំពោះគ្នាទៅវិញទៅមកនោះ គឺហៅថាកិច្ចសន្យាអញ្ញមញ្ញ។ រីឯកិច្ចសន្យាដែលភាគីតែម្ខាងមានកាតព្វកិច្ច ហើយភាគីម្ខាងទៀតគ្មានកាតព្វកិច្ចមានតែសិទ្ធិនោះគឺជាកិច្ចសន្យាឯកតោភាគី។ ប៉ុន្តែនៅទីនេះ គឺបើយើងមិនសិក្សាផ្តោតតែទៅលើកិច្ចសន្យាណាមួយនោះទេ យើងនឹងធ្វើការសិក្សាទៅលើលក្ខណៈជាទូទៅទាំងអស់នៃកិច្ចសន្យា។

#### ២.៣.១ អានុភាពបង្កើតសិទ្ធិទូទៅចំពោះភាគី

នៅរាល់បណ្តាកិច្ចសន្យាដែលមានសុពលភាព គឺតែងតែតម្រូវឱ្យភាគីនីមួយៗធ្វើនូវអ្វីមួយ ឬ ក៏មិនធ្វើអ្វីមួយ។[38] ពោលគឺជាទូទៅភាគីនីមួយៗនៃកិច្ចសន្យាមានសិទ្ធិ និង កាតព្វកិច្ចដើម្បីបំពេញទៅតាមកិច្ចសន្យានោះ។ តាមការពិតហេតុផលដែលភាគីបានបង្កើតកិច្ចសន្យាមួយឡើងជាធម្មតារាល់កិច្ចសន្យាទាំងអស់នៃកិច្ចសន្យាអញ្ញមញ្ញដែលបង្កើតដោយគូភាគីគឺគូភាគីតែងតែទាមទារឱ្យបំពេញនូវករណីកិច្ចចំពោះគ្នាទៅវិញទៅមក។ ដូច្នេះការដែលភាគីណាម្ខាងចង់ឱ្យភាគីម្ខាងទៀតបំពេញនូវករណីកិច្ចណាមួយនោះ លុះត្រាតែខ្លួនមានសិទ្ធិ ហើយសិទ្ធិនោះ ត្រូវស្របទៅនឹងករណីកិច្ចរបស់ភាគីម្ខាងទៀតផងដែរ។

#### ២.៣.២ អានុភាពចាប់បង្ខំនូវករណីកិច្ចទូទៅចំពោះភាគី

បណ្តាកិច្ចសន្យា ដែលអាចដាក់ឱ្យប្រតិបត្តិបានភាគច្រើន តម្រូវឱ្យភាគីត្រូវតែប្រតិបត្តិកិច្ចសន្យានោះ។[39] ការប្រតិបត្តិតាមកិច្ចសន្យាជាការអនុវត្តនូវរាល់អំពើរបស់ភាគីចុះកិច្ចសន្យា ដែលមានកាតព្វកិច្ចត្រូវតែប្រព្រឹត្តសំដៅបំពេញតម្រូវការចំពោះសិទ្ធិរដ្ឋប្បវេណីរបស់ភាគីម្ខាងទៀតដែលត្រូវទទួលបានត្រូវគ្នាជាមួយនិងកាតព្វកិច្ច

---

[37] មាត្រា ២២ នៃក្រឹត្យ-ច្បាប់លេខ ៣៨

[38] ច្បាប់កិច្ចសន្យាផ្សារសេរី

[39] ច្បាប់កិច្ចសន្យាផ្សារសេរី ឆ្នាំ ១៩៩៧

នោះ។[40]ម្យ៉ាងទៀតពេលចុះកិច្ចសន្យានោះភាគីនីមួយៗសុទ្ធតែមានវត្ថុបំណងរបស់ខ្លួនយ៉ាងពិតប្រាកដ ប៉ុន្តែគោលបំណងរបស់ខ្លួនដែលមានលទ្ធផលចេញពីកិច្ចសន្យានោះអាចសម្រេចបាន ឬ អត់ វាគឺអាស្រ័យដោយភាគីប្រតិបត្តិកាតព្វកិច្ចបានត្រឹមត្រូវពេញលេញទៅតាមការសន្យានោះ ឬយ៉ាងណា[41] ជារួមមានន័យថា កិច្ចសន្យាដែលដាក់ឱ្យប្រតិបត្តិទៅបានលុះត្រាតែកិច្ចសន្យានោះមានសុពលភាព។ ហើយដោយហេតុសុពលភាពនៃកិច្ចសន្យានោះហើយទើបបានធ្វើឱ្យកិច្ចសន្យាមួយមានអានុភាព។ ដូច្នេះអានុភាពនៃកិច្ចសន្យា ក៏បានបង្កើតឱ្យមានផងដែរនូវលក្ខណៈចាប់បង្ខំចំពោះគូភាគីឱ្យមាននូវករណីកិច្ចទូទៅមួយចំនួនជាកំហិត។

### ២.៣.២.១ កិច្ចសន្យាត្រូវតែអនុវត្ត

ក្រោយពីការកកើតនូវកិច្ចសន្យាហើយមកអានុភាពនៃកិច្ចសន្យាបានចាប់បង្ខំគូភាគីនៃ កិច្ចសន្យាឱ្យត្រូវតែអនុវត្តកិច្ចសន្យាដែលបង្កើតឡើងនោះ ក៏ដូចជាបានបញ្ជាក់ពីខាងដើមរួចមកហើយថា ហេតុផលដែលភាគីធ្វើកិច្ចសន្យាមួយឡើងតាមធម្មតា គឺភាគីប្រាកដថាភាគីម្ខាងនឹងបំពេញកាតព្វកិច្ចដែលភាគីម្ខាងទៀតចង់ឱ្យបំពេញ។ ដូច្នេះដើម្បីឱ្យគោលបំណងរបស់ភាគី នៃកិច្ចសន្យាអាចសម្រេចបាននោះ ភាគីចាំបាច់ត្រូវតែអនុវត្តកាតព្វកិច្ចបំពេញទៅតាមកិច្ចសន្យា។ បើយោងតាមមាត្រា ២៩ នៃក្រឹត្យច្បាប់លេខ ៣៨ បានកំណត់ថាកាតព្វកិច្ចទាំងឡាយ ដែលមានចែងក្នុងកិច្ចសន្យាត្រូវតែអនុវត្តយ៉ាងទៀងទាត់ និងត្រឹមត្រូវជាពិសេសអំពីបរិមាណគុណភាពទីកន្លែង និងរយៈពេលកំណត់។ មានន័យថា ក្នុងការអនុវត្តកិច្ចសន្យា ភាគីនៃកិច្ចសន្យាត្រូវតែអនុវត្តកិច្ចសន្យាឱ្យស្របទៅតាមខ្លឹមសារ និងការកំណត់ផ្សេងទៀត ដែលបានកំណត់តាមការព្រមព្រៀងក្នុងកិច្ចសន្យានោះ។ និយាយដោយខ្លីទៅគឺថាគូភាគីនៃកិច្ចសន្យាត្រូវធ្វើតាមអ្វីដែលមានចែងក្នុងកិច្ចសន្យាឱ្យបាន ១០០ ភាគរយ។ ពីព្រោះថាកិច្ចសន្យាគឺជាច្បាប់របស់គូភាគី។ ដូច្នេះគូភាគីចាំបាច់ត្រូវតែគោរពទៅតាមច្បាប់នោះជាដាច់ខាត ល្គឹកណា ដែលភាគីមិនអនុវត្តតាមច្បាប់ ដែលជាកិច្ចសន្យានោះ ទោះបីជាទាំងស្រុងក្តី ឬពាក់កណ្តាលក្តីនឹងនាំឱ្យមានទណ្ឌកម្មតាមផ្លូវច្បាប់គឺៈ ការរំលាយកិច្ចសន្យានិងសំណងជំងឺចិត្តជាដើមប្រសិនបើមាន។[42]

ជាងនេះទៀតសោត ការអនុវត្តកាតព្វកិច្ចក្នុងកិច្ចសន្យានោះគឺវាមានលក្ខណៈជាកាតព្វកិច្ចជាច្រើនប្រភេទខុសៗគ្នាទៅតាមបណ្តានៃកិច្ចសន្យានីមួយៗ ជាក់ស្តែងប្រភេទនៃកាតព្វកិច្ចនៅក្នុងក្រមរដ្ឋប្បវេណីថ្មីឆ្នាំ ២០០៧ ត្រូវបានគេបែងចែកចេញជា៣ ដូចជា កាតព្វកកិច្ចផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់លើវត្ថុ ឬប្រាក់ និងកាតព្វកិច្ចដែលមានគោលបំណងធ្វើ ឬមិនធ្វើសកម្មភាពណាមួយ។[43] ដូច្នេះទើបការអនុវត្តកាតព្វកិច្ចនីមួយៗមានលក្ខណៈខុសៗគ្នាអាស្រ័យទៅតាមប្រភេទនៃកាតព្វកិច្ចក្នុងកិច្ចសន្យានីមួយៗ។ បើករណី ដែលកិច្ចសន្យាបង្កើតអានុភាពឱ្យមានកាតព្វកិច្ចណាមួយហើយនោះ ភាគីនៃកិច្ចសន្យាត្រូវប្រតិបត្តិបំពេញទៅតាមប្រភេទនៃកាតព្វកិច្ចនោះ។

ជាក់ស្តែងចំពោះកាតព្វកិច្ចផ្ទេរកម្មសិទ្ធិ សិទ្ធិកាន់កាប់ ឬប្រាក់ ក្នុងការអនុវត្តកិច្ចសន្យាភាគីត្រូវបំពេញនូវករណីកិច្ចមួយចំនួនដូចជាៈ

[40] ច្បាប់កិច្ចសន្យាផ្សារសេរី ឆ្នាំ ១៩៩៧

[41] ច្បាប់កិច្ចសន្យាផ្សារសេរី ឆ្នាំ ១៩៩៧

[42] សៀវភៅអានុភាពនៃកិច្ចសន្យា សាស្ត្រាចារ្យៈមួន សៀងលី ទំព័រ៣១

[43] មាត្រា ៣១៣ ក្រមរដ្ឋប្បវេណី ២០០៧

ភាគីដែលមានកាតព្វកិច្ចត្រូវធ្វើការផ្ទេរសិទ្ធិ ព្រមទាំងករណីដែលមានការប្រគល់វត្ថុជាក់លាក់អ្វីមួយ កូនបំណុលមានករណីកិច្ចថែរក្សាវត្ថុនោះ ដោយប្រុងប្រយ័ត្នក្នុងនាមអ្នកគ្រប់គ្រងដ៏ល្អ រហូតដល់ពេលប្រគល់វត្ថុនោះ (ឧទាហរណ៍៖ កិច្ចសន្យាលក់ទិញរូបគំនូរ១ផ្ទាំងដ៏ល្បីរបស់កុមារីម្នាក់ដែលបានស្លាប់ទៅហើយ)។ លើសពីនេះទៅទៀត ក្នុងករណីដែលកិច្ចសន្យាពាក់ព័ន្ធនឹងសិទ្ធិប្រាតិភោគ ភាគីដែលជាម្ចាស់បំណុលបានកាន់កាប់វត្ថុរបស់កូនបំណុលក្នុងដៃរបស់ខ្លួន ដែលជាម្ចាស់បំណុលដែលបានកាន់កាប់វត្ថុរបស់កូនបំណុលក្នុងដៃរបស់ខ្លួនដើម្បីធានាសិទ្ធិលើបំណុលនោះ ក៏ត្រូវមានករណីកិច្ចថែរក្សាវត្ថុ ដែលបានដាក់ប្រាតិភោគឱ្យបានសមរម្យ និង គង់វង្សបានល្អដោយអនុវត្តឱ្យដូចខ្លួនជាម្ចាស់នៃវត្ថុនោះ ឬក៏ជាមាតាបិតាចំពោះកូនអញ្ចឹងដែរ (ឧទាហរណ៍៖ កិច្ចសន្យាបញ្ចាំ)។

ករណីបើសិនកម្មវត្ថុដែលត្រូវផ្តល់មានគុណភាពច្រើនយ៉ាង កូនបំណុលមានករណីកិច្ចផ្តល់វត្ថុដែលមានគុណភាពដូចដែលគូភាគីបានកំណត់ក្នុងកិច្ចសន្យា (ឧទាហរណ៍៖ កិច្ចសន្យាលក់ទិញឆ្នាំងដាំបាយអគ្គិសនីមួយគ្រឿងដែលក្នុងកិច្ចសន្យានោះបានកំណត់អំពី ប្រភេទម៉ាក និងទំហំគុណភាពរបស់វា។ ដូច្នេះបើទោះបីជាឆ្នាំងដាំបាយអគ្គិសនីរបស់អ្នកលក់មានច្រើនប្រភេទ ច្រើនម៉ាក និងមានគុណភាពផ្សេងៗពីគ្នាច្រើនយ៉ាងណាក៏ដោយ ក៏អ្នកលក់ចាំបាច់ត្រូវតែផ្តល់នូវវត្ថុដែលមានគុណភាពស្របទៅតាមខ្លឹមសារនៃកិច្ចសន្យាជាកំហិត។ ប៉ុន្តែបើភាគីមិនបានកំណត់ទេ កូនបំណុលមានករណីកិច្ចផ្តល់នូវវត្ថុដែលមានគុណភាពមធ្យម។ ម្យ៉ាងទៀត ភាគីដែលទទួលបន្ទុកទំនាក់ទំនងគតិយុត្តដែលទាក់ទងទៅនិងកម្មវត្ថុនៃការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់ត្រូវមានករណីកិច្ចពន្យល់ឱ្យបានច្បាស់លាស់អំពីសិទ្ធិ និងបញ្ហាទាំងឡាយដែលពាក់ព័ន្ធទៅនឹងកម្មវត្ថុនៃកិច្ចសន្យានោះ (ឧទាហរណ៍៖ កិច្ចសន្យាលក់ទិញអចលនវត្ថុអ្នកលក់ត្រូវតែពន្យល់អំពីការប្រើប្រាស់ និងទំហំនៃអចលនវត្ថុនោះជាដើម)។ ហើយភាគីដែលមានបន្ទុកកាតព្វកិច្ចក្នុងប្រភេទនេះត្រូវមានករណីកិច្ចផ្តល់វត្ថុ ឬ សិទ្ធិផ្សេងទៀត ដែលជាកម្មវត្ថុនៃកិច្ចសន្យាដោយគ្មានវិការៈ។[44]

### ២.៣.២.២ ការអនុវត្តត្រូវតែគោរពគោលការណ៍សុចរិតនិងស្មោះត្រង់

នៅរាល់បណ្តាច្បាប់ជាតិរបស់សង្គមជាតិនីមួយៗ និងច្បាប់អន្តរជាតិនៃសហគមន៍ប្រជាជាតិផងដែរនោះយើងបានសង្កេតឃើញថា មានគោលការណ៍ដ៏សំខាន់មួយដែលមានការទទួលស្គាល់ជាទូទៅមួយភាគធំតាមរយៈការអនុវត្តដោយបណ្តាប្រទេសជាច្រើនក្នុងសកលលោក នោះគឺជាគោលការណ៍នៃភាពសុចរិតនិងស្មោះត្រង់។[45] នៅក្នុងសង្គមអន្តរជាតិ គោលការណ៍នេះឃើញមានការប្រើប្រាស់ជាញឹកញាប់នៅក្នុងការអនុវត្តសន្ធិសញ្ញា និង កិច្ចព្រមព្រៀងនានាសម្រាប់ការធានាបាននូវការអនុវត្តមួយដែលត្រឹមត្រូវ និងសមស្របប្រកបដោយសមធម៌ល្អប្រពៃ។ ជាក់ស្តែងនៅកម្ពុជា ក្នុងច្បាប់កិច្ចសន្យា ក៏បានធានាឱ្យគោរព នូវគោលការណ៍នេះផងដែរក្នុងការអនុវត្ត។ នៅក្នុងមាត្រា ២ នៃក្រឹត្យច្បាប់ លេខ ៣៨ របស់កម្ពុជាបានចែងថា កិច្ចសន្យាទាំងឡាយ ត្រូវរួមចំណែកក្នុងការផ្សាភ្ជាប់ផលប្រយោជន៍បុគ្គល និងផលប្រយោជន៍សង្គម។ ភាគីនៃកិច្ចសន្យាត្រូវសហការគ្នាក្នុងបរិយាកាសទុកចិត្តស្មោះត្រង់នឹងគ្នាអនុវត្តសមស្របនិង គោលការណ៍សីលធម៌សង្គម ហើយ

[44] សៀវភៅអានុភាពនៃកិច្ចសន្យា សាស្ត្រាចារ្យ៖មួន សៀងលី ឆ្នាំ ២០១២

[45] អនុសញ្ញាទីក្រុងវីយែនឆ្នាំ ១៩៦៩ ស្តីពីច្បាប់សន្ធិសញ្ញា

ពិសេសកម្ចាត់ចោលនូវគំនិត មនុស្សជិះជាន់មនុស្ស។ បន្ថែមពីលើមាត្រានេះ មាត្រា ២២ ចាខណ្ឌទី ២ នៃក្រឹត្យច្បាប់លេខ ៣៨ ដដែល ក៏បានចែងដែរថាកិច្ចសន្យាត្រូវយកទៅអនុវត្តដោយសុចរិត និង ស្មោះត្រង់។ ដោយយោងតាមរយៈនៃមាត្រាទាំង ២ នេះ វាបានឆ្លុះបង្ហាញឱ្យឃើញពីគោលការណ៍នៃភាពសុចរិត និង ស្មោះត្រង់ក្នុងការអនុវត្តកិច្ចសន្យា។ លើសពីនេះទៅទៀត ក្រមរដ្ឋប្បវេណីថ្មីឆ្នាំ ២០០៧ ក្នុងមាត្រា (៣៨៤) ក៏បានទទួលស្គាល់នូវគោលការណ៍នេះផងដែរ។ នៅក្នុងមាត្រា ៣៨៤ កថាខណ្ឌទី១នោះ បានបញ្ញត្តិថាៈ កូនបំណុលត្រូវតែអនុវត្តកាតព្វកិច្ចរបស់ខ្លួន ឱ្យស្របទៅតាមខ្លឹមសារនៃកិច្ចសន្យា និងគោលការណ៍នៃភាពសុចរិត និង ភាពស្មោះត្រង់។

ការប្រតិបត្តិដោយសុចរិត និងស្មោះត្រង់នៅទីនេះមានន័យថាភាគីម្ខាងៗនៃកិច្ចសន្យាមិនត្រូវធ្វើអ្វីឱ្យល្អក់កករដល់ការប្រតិបត្តិកាតព្វកិច្ចរបស់ភាគីម្ខាងទៀតឡើយ។ និយាយជារួមគឺថាភាគីម្នាក់ៗត្រូវតែប្រកាន់ភ្ជាប់យកនូវឥរិយាបទសមស្របត្រឹមត្រូវជៀសវាងធ្វើអ្វីដែលនាំឱ្យភាគីម្ខាងពិបាក ឬ ពុំអាចបំពេញកាតព្វកិច្ចបានពោលគឺភាគីម្ខាងត្រូវសម្រួលដល់ការសម្រេចបានក្នុងការអនុវត្តកាតព្វកិច្ចរបស់ភាគីម្ខាងទៀត។ ការរារាំងដោយមិនសមស្របនូវការអនុវត្តរបស់ភាគីម្ខាងនោះ មាត្រា ៣២៨ បានកំណត់ថាប្រសិនបើភាគីដែលនឹងខូចប្រយោជន៍ដោយសារលក្ខខ័ណ្ឌត្រូវបានបំពេញហើយភាគីនោះបានរារាំងមិនឱ្យល័ក្ខខ័ណ្ឌ ត្រូវបានបំពេញដោយចេតនាភាគីម្ខាងទៀតអាចចាត់ទុកថាលក្ខខ័ណ្ឌនោះត្រូវបានបំពេញរួចហើយ។[46] ឧទាហរណ៍ៈ កិច្ចសន្យាប្រទានកម្មដែលមានបង្អង់លក្ខខណ្ឌមួយបានកំណត់ បើសិនជា A រៀបអាពាហ៍ពិពាហ៍ជាមួយនឹងកូនរបស់B និងប្រគល់ឱ្យនូវដីឡូត៍មួយកន្លែងឱ្យ A ប៉ុន្តែក្រោយមកដោយសារតែដីនោះបានកើនតម្លៃកាន់តែខ្ពស់ខ្លាំងពេលនោះ B ក៏បានផ្លាស់ប្តូរចិត្តមិនចង់ប្រគល់ដីនោះទៅឱ្យ A។ ដូច្នេះ B ក៏បានព្យាយាមរារាំង A មិនឱ្យអនុវត្តសម្រេចបាននូវល័ក្ខខ័ណ្ឌបង្អង់នោះ។ ជាដំណោះស្រាយ យោងតាមមាត្រា ៣២៨ ខាងលើដោយ B បានរារាំងមិនឱ្យល័ក្ខខ័ណ្ឌត្រូវបានបំពេញដោយចេតនាបែបនេះនាំឱ្យ A អាចចាត់ទុកថា លក្ខខណ្ឌនោះត្រូវបានបំពេញរួចហើយ។

យើងអាចនិយាយបានថាដោយផ្អែកតាមស្មារតីនៃភាពសុចរិត និងស្មោះនៃបទប្បញ្ញត្តិខាងលើនេះ គូភាគីមានកាតព្វកិច្ចមួយក្នុងការសហការគ្នាក្នុងការប្រតិបត្តិកាតព្វកិច្ចរៀងខ្លួនៗឱ្យបានល្អ និង មិនកេងចំណេញខុសពីច្បាប់ឡើយ។

ឧទាហរណ៍ៈ ម្ចាស់រថយន្តឈ្នួល A បានធ្វើកិច្ចសន្យាដឹកជញ្ជូនមួយជាមួយ B ដោយសន្យាថានឹងដឹក B ដល់កន្លែងមួយជាកំណត់ប៉ុន្តែក្នុងការអនុវត្តកាតព្វកិច្ច A បានបើកបរតាមផ្លូវវាងដើម្បីទទួលបាននូវកម្រៃច្រើនៗ ដូច្នេះ តាមការអនុវត្តរបស់ A បែបនេះ ត្រូវចាត់ទុកថាជាការបំពេញកាតព្វកិច្ចដោយទុច្ចរិត។ ដូចគ្នានេះដែរនៅក្នុងកិច្ចសន្យាធានារ៉ាប់រងអ្នកត្រូវបានគេធានារ៉ាប់រងអនុវត្តកិច្ចសន្យាដោយទុច្ចរិតនៅពេលដែលជននេះប្រើប្រាស់នូវអំពើនៃបន្លំក្នុងគោលបំណងឱ្យកើតគ្រោះភ័យហើយខ្លួនទទួលបាននូវសំណងនៃការខូចខាត។

[46] មាត្រា ៣២៨ ស្តីពី លក្ខខ័ណ្ឌ នៃក្រមរដ្ឋប្បវេណី ២០០៧

## ២.៤ អានុភាពបង្កើតជាច្បាប់របស់ភាគី

កិច្ចសន្យាដែលបង្កើតឡើងតាមរយៈការព្រមព្រៀងរបស់ភាគី បានបង្កឱ្យមាននូវអានុភាពនៃការជៀប ទៅលើកិច្ចសន្យានោះឱ្យទៅជាច្បាប់របស់គូភាគី។[47] កិច្ចសន្យាដែលច្បាប់របស់ភាគីគឺជាវិធានគតិយុត្តទាំងឡាយណាដែលគ្រប់គ្រងរាល់ទំនាក់ទំនងរបស់ភាគីនៅក្នុងកិច្ចសន្យា។ ការបង្កើតកិច្ចសន្យាឡើងភាគីនីមួយៗនៃកិច្ចសន្យាបានរួបរួមគ្នាយ៉ាងសកម្មក្នុងការព្រមព្រៀងអនុម័តសម្រេច នូវវិធានទាំងឡាយដែលបានកំណត់ក្នុងកិច្ចសន្យារបស់ពួកគេ។ ដូច្នេះជាគោលការណ៍ទូទៅ កិច្ចសន្យាមិនអាចត្រូវបានធ្វើការកែប្រែទៅតាមទំនើងចិត្ត ឬជាសកម្មភាពឯកតោភាគីដោយឯកឯងបាននោះឡើយ។ លើសពីនេះទៅទៀតនោះគឺភាពមិនអាចបំពានបាននៃកិច្ចសន្យាដោយផ្អែកលើវិធានដែលគ្រប់គ្រង លើកិច្ចសន្យាប្រសិនមានករណីបំពារបំពានលើកិច្ចសន្យានោះ វានឹងមានអានុភាពអាចឈានដល់ការដាក់ទណ្ឌកម្ម (ការរំលាយកិច្ចសន្យា ឬ សំណងការខូចខាតជាដើម)។

### ២.៤.១ ភាពមិនអាចកែប្រែបាននៃកិច្ចសន្យា

ជាគោលការណ៍ទូទៅ កិច្ចសន្យាមិនត្រូវបានអនុញ្ញាតឱ្យធ្វើការកែប្រែបានឡើយ។ ប៉ុន្តែក៏មានករណីអញ្ញាត្រកម្មមួយចំនួនទៅលើគោលការណ៍នេះផងដែរ។ ដូច្នេះប្រសិនបើមានអញ្ញត្រកម្មអនុញ្ញាតឱ្យកិច្ចសន្យាអាចធ្វើការកែប្រែបាននោះ ការកែប្រែអាចស្តែងឡើងក្រោមរូបភាពពីរផ្សេងៗគ្នាគឺ ៖

១.ការកែប្រែចំណុចមួយចំនួននៃកិច្ចសន្យា និង

២.ការកែប្រែទាំងស្រុងនៃកិច្ចសន្យា ពោលគឺ ការកាត់ផ្តាច់ចំណងកិច្ចសន្យាចោល។

ជាក់ស្តែងនៅក្នុងមាត្រា ២២ នៃក្រឹត្យច្បាប់លេខ ៣៨ បានបញ្ញត្តិថា៖

កិច្ចសន្យាគឺជាច្បាប់របស់ភាគី។ កិច្ចសន្យានឹងអាចកែប្រែបាន លុះត្រាតែមានការយល់ព្រមរបស់គូភាគីទាំងសងខាង។យោងតាមរយៈមាត្រានេះនិងការអត្ថាធិប្បាយខាងលើរួចមកហើយនោះគឺអាចធ្វើឱ្យយើងដឹងថាកិច្ចសន្យាគឺជាអាចត្រូវបានអនុញ្ញាតឱ្យធ្វើការកែប្រែ តាមទំនើងចិត្តជាឯកតោភាគីបានឡើយ។ច្បាប់ដែលកើតចេញពីឆន្ទៈទូទៅរបស់ភាគីនៃកិច្ចសន្យា[48] ហើយកិច្ចសន្យាមិនអនុញ្ញាតអោយធ្វើការកែប្រែតាមទំនើងចិត្តជាឯកតោភាគីបានឡើយ។

### ២.៤.២ ភាពមិនអាចបំពានបាននៃកិច្ចសន្យា

តើអ្វីទៅជាការបំពានកិច្ចសន្យា? ការបំពានកិច្ចសន្យាគឺជាការខកខានពុំបានបំពេញកាតព្វកិច្ចទៅតាមការសន្យាណាមួយ ដែលភាគីមួយបានធ្វើឡើងនៅក្នុងកិច្ចសន្យា នៅពេលដែលបំពេញកាតព្វកិច្ចតាមការសន្យាបានមកដល់កំណត់កាលត្រូវបំពេញ ឬ អាចនិយាយឱ្យខ្លីហៅថាការមិនអនុវត្តកាតព្វកិច្ច។ ការមិនអនុវត្តកាតព្វកិច្ចនេះ បានធ្វើការបែងចែកចេញជា ៣ផ្សេងៗទៀត ដូចជា ការអនុវត្តយឺតយ៉ាវ អលទ្ធភាពក្នុងការអនុវត្តការអនុវត្តមិនពេញលេញ និង ករណីផ្សេងទៀតដែលមិនអនុវត្ត ។ យ៉ាងណាមិញ អានុភាពតាមផ្លូវច្បាប់ស្តីពីការបំពានកិច្ចសន្យានេះ គឺវាបានកំណត់ផ្សេងៗពីគ្នាយោងទៅលើថា តើការបំពាននោះវាធ្ងន់ធ្ងរយ៉ាងដូចម្តេច?

---

[47] ច្បាប់រដ្ឋប្បវេណី (ករណីប្រទេសជប៉ុន)

[48] គោលគំនិតនៅក្នុងទ្រឹស្តីរបស់ទស្សនវិទូជនជាតិបារាំង លោក ស្សង់ ស្សាក់រូសូ

ដោយជាក់លាក់ អានុភាពទៅតាមផ្លូវច្បាប់នោះ គឺអាស្រ័យលើថាតើការបំពានមួយវាជាខ្លឹមសារសំខាន់ ឬ ក៏តូចតាច។

ជាក់ស្តែង នៅក្នុងមាត្រា ៤០៨ នៃក្រមរដ្ឋប្បវេណី២០០៧ បានកំណត់ពីការបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ។ ក្រោយយើងពីបានយល់ដឹងពីខ្លឹមសារនៃការបំពានកិច្ចសន្យាហើយមកគឺអាចធ្វើឱ្យយើងបានដឹងថា ការបំពានកិច្ចសន្យា មិនមែនជារឿងដ៏ល្អឡើយសម្រាប់សម្រេចបាននូវគោលបំណងនៃកិច្ចសន្យា។ មានន័យថា បើសិនជាមានការបំពានកិច្ចសន្យាកើតឡើងគោលបំណងនៃកិច្ចសន្យាគឺ ប្រាកដណាស់ពិតជាមិនបានសម្រេចនោះទេ។ ដូច្នេះនៅពេលដែលកិច្ចសន្យាមួយត្រូវបានបង្កើតឡើង ដោយមានសុពលភាពតាមផ្លូវច្បាប់ហើយ គូភាគីត្រូវតែគោរពឱ្យបានម៉ត់ចត់។ នេះជាអ្វីដែលហៅថា អានុភាពដាច់ខាតនៃកិច្ចសន្យា។ ជាសំណួរចោទឡើងថា តើយើងត្រូវធ្វើដូចម្តេចប្រសិនបើភាគីម្ខាងទៀតមិនគោរព ហើយមិនអនុវត្តកិច្ចសន្យាទេ? ជាការពិតណាស់, យើងអាចទៅពឹងពាក់តុលាការបង្ខំឱ្យភាគីម្ខាងទៀតគោរពតាមកិច្ចសន្យា (ការអនុវត្តដោយបង្ខំ) ក៏បានដែរ។ បន្ថែមពីនេះ ដើម្បីឱ្យអានុភាពនៃកិច្ចសន្យាមានអត្ថន័យពេញលេញនោះ ការបំពានយ៉ាងធ្ងន់ធ្ងរទៅលើកិច្ចសន្យាត្រូវតែដាក់ទណ្ឌកម្ម។ នៅក្នុងក្រមរដ្ឋប្បវេណី វិធីសង្គ្រោះចំពោះការបំពានកិច្ចសន្យា យើងមានមធ្យោបាយ ២ បែប។ បែបទី១៖ គឺរំលាយកិច្ចសន្យាដោយហេតុថាភាគីម្ខាងទៀតមិនអនុវត្តកាតព្វកិច្ច។ បែបទី២៖ គឺទាមទាមឱ្យភាគីសងសំណងនៃការខូចខាត ដែលកើតចេញពីការមិនអនុវត្តកាតព្វកិច្ច។ នៅក្នុងក្រមរដ្ឋប្បវេណីអនុញ្ញាតឱ្យជ្រើសរើសការរំលាយកិច្ចសន្យាក៏បាន ឬរើសយកការទាមទារសំណងក៏បាន ឬ ក៏អាចរើសយកទាំង ២ ក៏បានដែរក្នុងទំហំដែលមិនផ្ទុយគ្នា។

សូមបញ្ជាក់ថា សំណងនៃការខូចខាតត្រូវបានចែកចេញជា២ប្រភេទដូចជាសំណងខូចខាតជំនួស (ករណីអលទ្ធភាព) និងសំណងខូចខាតចំពោះការយឺតយ៉ាវ។ ការបែងចែកនេះមានន័យថា ដើម្បីឱ្យយើងដឹងពីវិសមតិភាពរវាងសំណងខូចខាតជំនួស និង ការទាមទារឱ្យអនុវត្តកាតព្វកិច្ច។ ការដាក់ទណ្ឌកម្មចំពោះការបំពានកិច្ចសន្យានេះអាចធ្វើទៅបានជាដំបូងនោះ យើងត្រូវសិក្សាទៅលើការទទួលខុសត្រូវក្នុងកិច្ចសន្យា។[49]

## ២.៥ កិច្ចសន្យាដែលធ្វើឡើងសម្រាប់តតិយជន

ឧទាហរណ៍៖ ដូចជាការសន្យាបន្ថែមនៅក្នុងការទិញលក់រវាងឈ្មោះ A និងឈ្មោះ B ដែលកំណត់ថានឹងបង់ប្រាក់ថ្លៃទំនិញឱ្យទៅឈ្មោះ C ផ្ទាល់ជាដើម ។ កិច្ចសន្យាដែលផ្តល់ផលប្រយោជន៍ ទៅតតិយជនក្រៅពីភាគីនៃកិច្ចសន្យានេះគេហៅថា កិច្ចសន្យាដែលធ្វើឡើងសម្រាប់តតិយជន[50] (ចាប់ពីមាត្រា ៥៣៧ តទៅ) ។ នេះជាកិច្ចសន្យាមួយ ក៏ប៉ុន្តែកិច្ចសន្យានេះមិនអាចកើតមានឡើងដោយឯកឯងទេ តោងភ្ជាប់ទៅនឹងកិច្ចសន្យាណាមួយទៀត ហើយមានឈ្មោះជាកិច្ចសន្យាពិសេស ឬក៏ជាកថាលក្ខន្តិកៈបន្ទាប់បន្សំ។ ដោយហេតុថា វាញ៉ាំងឱ្យកិច្ចសន្យាមានអានុភាពចងចំពោះជនផ្សេងក្រៅពីភាគីនៃកិច្ចសន្យានោះ គេចាត់ទុកនេះថា ជាករណីលើកលែងដែលខុសពីការយល់ដឹងជាទូទៅចំពោះអានុភាពនៃកិច្ចសន្យា (មិនជះឥទ្ធិពលទៅលើជនណាក្រៅពីតួនាទីទេ)។ ប៉ុន្តែក្នុងករណីនេះក៏មានការកំណត់ព្រំដែនដូចតទៅ:

[49] សៀវភៅអានុភាពនៃកិច្ចសន្យា ជំពូកទី១ សាស្ត្រាចារ្យ៖មួន សៀងលី ទំព័រ៤៣

[50] ច្បាប់ស្តីពីសិទ្ធលើបំណុល (ជំពូកទី៤)

**ក.** អាចធ្វើកិច្ចសន្យាបានដោយឱ្យផលប្រយោជន៍ដល់តតិយជន C តែមិនអាចធ្វើការព្រមព្រៀងគ្នាបង្កឱ្យតតិយជន C ទទួលរងនូវផលវិបាកដោយត្រូវបំពេញកាតព្វកិច្ចជាអវិជ្ជមានណាមួយឡើយ ។

**ខ.** តតិយជន C ដែលជាអ្នកទទួលផលនោះមិនអាចនឹងទទួលផលប្រយោជន៍ដែលកើតឡើងតាមរយៈការព្រមព្រៀងគ្នារវាងឈ្មោះ A និង ឈ្មោះ B ដោយស្វ័យប្រវត្តិបានទេ ពោលគឺចាំបាច់ត្រូវតែតតិយជន C បង្ហាញឆន្ទៈព្រមទទួលផលផងដែរ (ការបង្ហាញឆន្ទៈក្នុងការទទួលផលប្រយោជន៍) ។

**គ.**បើតតិយជន C បង្ហាញឆន្ទៈក្នុងការទទួលផលប្រយោជន៍ហើយ ភាគី A និង B មិនអាចដកការព្រមព្រៀងនេះចេញបានទេ តែបើមិនទាន់មានការបង្ហាញឆន្ទៈទទួលផលពីតតិយជន C នៅឡើយទេ ការព្រមព្រៀងអាចដកចេញវិញបាន។

ម្យ៉ាងទៀត បន្ទាប់ពីបានបង្ហាញឆន្ទៈទទួលផលហើយ តតិយជនដែលជាអ្នកទទួលផលអាចទាមទារឱ្យកូនបំណុលផ្តល់តាវកាលិកមកខ្លួនដោយចំពោះបាន។ នៅក្នុងករណីនេះកូនបំណុលអាចអះអាងនូវគ្រប់សិទ្ធិទាំងអស់ ដូចដែលខ្លួនមានទៅលើម្ចាស់បំណុលនោះបានដែរ (មានន័យថាឧទាហរណ៍៖ ដូចជាក្នុងករណីអ្នកលក់ A និងអ្នកទិញ B បានធ្វើកិច្ចសន្យាលក់ជាមួយគ្នាហើយ បានធ្វើកិច្ចសន្យាសម្រាប់តតិយជនដោយកំណត់ថា ត្រូវប្រគល់ប្រាក់ថ្លៃទំនិញទៅឱ្យឈ្មោះ C ផ្ទាល់ថែមទៀតផង។ ក្រោយពីឈ្មោះ C បានបង្ហាញឆន្ទៈថាសុខចិត្តទទួលផលប្រយោជន៍ហើយ ឈ្មោះ C ទៅទារប្រាក់ថ្លៃទំនិញពី B ។ បើសិនជា B នៅមិនទាន់បានទទួលទំនិញពី A នៅឡើយទេហើយមានសិទ្ធិតវ៉ាជាមួយ A ទាមទារឱ្យអនុវត្តព្រមគ្នានោះ B ក៏អាចប្រើសិទ្ធិតវ៉ានេះចំពោះ C បានដូចគ្នាផងដែរ) ។

## ២.៦ អានុភាពនៃកិច្ចសន្យាចំពោះតតិយជន

កិច្ចសន្យា ដែលបង្កើតឡើងដោយឆន្ទៈព្រមព្រៀងរបស់ភាគីត្រូវចាត់ទុកថាជាច្បាប់របស់ភាគីដូច្នេះ វាបង្កើតឱ្យមានអានុភាពត្រឹមតែចំពោះភាគីតែប៉ុណ្ណោះ។ តាមរយៈនេះកិច្ចសន្យាមិនមានចំណងគតិយុត្តជាមួយតតិយជនឡើយ ព្រោះថាតតិយជនជាជនទាំងឡាយណាដែលស្ថិតនៅក្រៅកិច្ចសន្យា។ ដូច្នេះជាទូទៅអានុភាពនៃកិច្ចសន្យាមិនមានអានុភាពចំពោះតតិយជននោះទេ។[51] ជាអញ្ញាត្រកម្មច្បាប់ក៏មានចែងនូវបទប្បញ្ញត្តិពិសេសមួយចំនួន ដែលកំណត់អំពីអានុភាពនៃកិច្ចសន្យាបានជះឥទ្ធិពលទៅលើតតិយជនផងដែរ។

ជាក់ស្តែងគោលការណ៍ និងបទប្បញ្ញត្តិរបស់ច្បាប់មួយ ចំនួន ក៏បានចែងពីអានុភាពនៃកិច្ចសន្យាចំពោះតតិយជនក្នុងករណីមួយចំនួនផងដែរ។ ជាទូទៅតតិយជនអាចមានច្រើនប្រភេទហើយតតិយជនមួយចំនួនអាចក្លាយជាភាគីនៃកិច្ចសន្យាថែមទៀតផងក្នុងនោះមានដូចជា៖

**១.**ប្រតិសិទ្ធិសាកល និងប្រតិសិទ្ធិមានកំណត់

**២.**អ្នកទទួលផលប្រយោជន៍

**៣.**អ្នកតំណាងគ្មានសិទ្ធិ និង

**៤.**តតិយជនដាច់ខាត។

[51] សៀវភៅអានុភាពនៃកិច្ចសន្យា ជំពូកទី២ សាស្ត្រាចារ្យះមួន សៀងលី ទំព័រ៥៥

### ២.៦.១ កិច្ចសន្យាដែលបង្កើតស្ថានភាពគតិយុត្តចំពោះតតិយជន

កិច្ចសន្យាមួយចំនួន បង្កើតជាស្ថានភាពគតិយុត្តចំពោះតតិយជនដែលយើងអាចចាត់ទុកបានថាជាព្រឹត្តការណ៍គតិយុត្តសម្រាប់តតិយជន។ អាស្រ័យហេតុនេះ តតិយជនអាចលើកសំអាងពីកិច្ចសន្យា ទុកដូចជាភស្តុតាងសម្រាប់អះអាង ឬ បញ្ជាក់នូវសិទ្ធិណាមួយរបស់ខ្លួន ឬ សម្រាប់ដោះបន្ទុករបស់ខ្លួន។ ដូចគ្នានេះដែរ កិច្ចសន្យានឹងបង្កើតនូវស្ថានភាពគតិយុត្តដែលតតិយជនមិនអាចបដិសេធមិនទទួលស្គាល់ឡើយ។ កិច្ចសន្យាដែលបង្កើតស្ថានភាពគតិយុត្តចំពោះតតិយជនបែបនេះ តតិយជនទាំងនោះច្រើនតែជា ប្រតិសិទ្ធិសាកល និង ប្រតិសិទ្ធិមានកំណត់។[52]

**ក**.ប្រតិសិទ្ធិសាកល

ប្រតិសិទ្ធិសាកល គឺជាអ្នកទទួលសិទ្ធិបន្តពីគេដើម្បីប្រកបការរបស់ខ្លួនផងនិងជំនួសគេផង ដែលទទួលបានសិទ្ធិបេតិកភណ្ឌមួយភាគ ឬ ទាំងអស់ដែលរួមមានសិទ្ធិផង និង កាតព្វកិច្ចផង ពោលគឺ ទ្រព្យសកម្មផង និង អសកម្មផង។[53]

ឧទាហរណ៍៖ សន្តតិជនដែលមានអត្ថិភាពព្រមទទួលទាំងអស់នូវទ្រព្យសម្បត្តិរបស់មតកជន ។ ដូច្នេះ នៅពេលមតកជនស្លាប់ទៅ សន្តតិជន (ប្រតិសិទ្ធិសាកល)នឹងទទួលបាននូវសិទ្ធិ និងកាតព្វកិច្ចទាំងឡាយចេញពីកិច្ចសន្យាដែលធ្វើដោយមតកជនមុនពេលស្លាប់។ ឧទាហរណ៍៖ កិច្ចសន្យាផលុបភោគដែលមានការកំណត់កាលរំលត់ ទោះបីជាអសារកម្មសិទ្ធិករទទួលមរណភាពយ៉ាងណាក៏ដោយ បើមិនទាន់កាលកំណត់នៃកិច្ចសន្យាត្រូវរលត់ទេ សន្តតិជនដែលជាប្រតិសិទ្ធិសាកលរបស់អសារកម្មសិទ្ធិករនៅតែត្រូវទទួលស្គាល់ និង គោរពអនុវត្តកិច្ចសន្យានោះ បន្តរហូតដល់កាលកំណត់ពិតប្រាកដមកដល់។ នៅខណៈពេលនោះប្រតិសិទ្ធិសាកល នឹងក្លាយទៅជាភាគីនៃកិច្ចសន្យាដោយស្វ័យប្រវិត្ត។

ជាអញ្ញាត្រកម្ម គឺភាគីអាចកំណត់ក្នុងកិច្ចសន្យាថា មិនឱ្យមានអានុភាពដល់ទាយាទរបស់គូភាគីបាន ហើយកិច្ចសន្យាដែលបានចុះដោយយោងទៅលើគុណភាពផ្ទាល់របស់ភាគីម្ខាង មិនលាតសន្ធឹងអានុភាពដល់ប្រតិសិទ្ធិសាកលរបស់ភាគីនៃកិច្ចសន្យានោះ។ ម្យ៉ាងទៀតករណីកិច្ចសន្យាមួយចំនួន ដែលត្រូវរលត់ដោយសារតែមរណភាពរបស់ភាគីណាម្នាក់ដូចជាៈ កិច្ចសន្យាការងារ និង កិច្ចសន្យាអាណត្តិជាដើម។

**ខ**.ប្រតិសិទ្ធិមានកំណត់

ប្រតិសិទ្ធិមានកំណត់គឺជា បុគ្គលដែលទទួលបាននូវសិទ្ធិនិងកាតព្វកិច្ចមួយឬច្រើនជាកំណតច្បាស់លាស់លើបេតិកភ័ណ្ឌរបស់ម្ចាស់សិទ្ធិ ។ ឧទាហរណ៍៖ អច្ច័យទានមានកំណត់ អ្នកទិញ ឬ អ្នកទទួលអំណោយជាដើម។ពេលខ្លះប្រតិសិទ្ធិនេះ ក៏មានការពាក់ព័ន្ធនឹងកិច្ចសន្យា ដែលធ្វើឡើងដោយម្ចាស់សិទ្ធិដើម។ ចំពោះប្រតិសិទ្ធិមានកំណត់នេះ យើងត្រូវសិក្សាលើការផ្ទេរកិច្ចសន្យាទាក់ទងនឹងសិទ្ធិបាតិបុគ្គលនិងកិច្ចសន្យាទាក់ទងនឹងសិទ្ធិប្រត្យក្ស។

១.សិទ្ធិបាតិបុគ្គល

[52] សៀវភៅ អានុភាពនៃកិច្ចសន្យា ជំពូកទី២ (សាស្ត្រាចារ្យះមួន សៀងលី ) ទំព័រ៥៦

[53] សៀវភៅ អានុភាពនៃកិច្ចសន្យា ជំពូកទី២ (សាស្ត្រាចារ្យះមួន សៀងលី ) ទំព័រ៥៦

ជាគោលការណ៍មិនអនុញ្ញាត ឱ្យមានការផ្ទេរសិទ្ធិបាតិបុគ្គលបានទេគេមិនអាចផ្ទេរទាំងសិទ្ធិទាំងកាតព្វកិច្ចដែលកើតចេញពីកិច្ចសន្យារបស់ម្ចាស់បំណុលបានទេ។ ឧទាហរណ៍៖ លោក A បានលក់រថយន្តមកឱ្យលោក B ប៉ុន្តែលោក A បានជំពាក់ប្រាក់ថ្លៃជួសជុលរថយន្តជាមួយលោក C ។ ដូច្នេះសិទ្ធិបាតិបុគ្គលដែលលោក A ជំពាក់លោក C នេះ មិននាំឱ្យលោក B ត្រូវបន្តទទួលខុសត្រូវថ្លៃជួសជុលលើរថយន្តនេះទេ។

ផ្ទុយទៅវិញ បើសិនជាលោក B បានដឹងពីការជួសជុលនោះ ហើយបានយល់ព្រមទទួលយកកាតព្វកិច្ចនៃការសងជំនួស A ដោយសារការបន្ថយតម្លៃពិតប្រាកដលើរថបរន្តដែលជាកម្មវត្ថុនៃការលក់ទិញ។ ដូច្នេះករណីនេះ លោក B នឹងត្រូវទទួលខុសត្រូវបន្តលើកាតព្វកិច្ចនៃថ្លៃជួសជុលរថយន្ត នោះ។ ឧទាហរណ៍៖ បន្ទាប់ A ម្ចាស់ផ្ទះបានចុះកិច្ចសន្យា ផលុបភោគជាមួយនឹង B ។ ក្រោយមក A លក់ផ្ទះនោះទៅឱ្យ C ។ C ជាប្រតិសិទ្ធិមានកំណត់របស់ A ដែលជាម្ចាស់សិទ្ធិដើម។ ចំពោះកិច្ចសន្យារវាង A និង B , C ជាតតិយជនដែលពុំមានអ្វីជាប់ទាក់ទងនឹងកិច្ចសន្យានោះឡើយ។ ប៉ុន្តែ ច្បាប់ភូមិបាលឆ្នាំ ២០០១ ការលក់អចលនវត្ថុដែលកំពុងជាប់ផលុបភោគដោយសារ កម្មសិទ្ធិករ មិនធ្វើឱ្យមានការផ្លាស់ប្តូរណាមួយចំពោះផលុបភោគដែលកំពុងបន្ត ប្រើប្រាស់សិទ្ធិរបស់ខ្លួននោះទេ។[54] ហេតុនេះ C ត្រូវតែទទួលស្គាល់អត្ថិភាពនៃសិទ្ធិ ផលុបភោគដែលមានស្រាប់នៅលើទ្រព្យដែលខ្លួនទិញ ។ លើសពីនេះ ក៏មានករណីមួយចំនួនទៀតផងដែរដូចជា៖

» ភតិសន្យា អ្នកទិញអចលនវត្ថុដែលបានជួល ត្រូវបន្តគោរពកិច្ចសន្យាជួល។[55]

» កិច្ចសន្យាការងារ អ្នកទិញ រោងចក្រសហគ្រាសត្រូវបន្តគោរពកិច្ចសន្យាការងាររវាងកម្មករនិយោជិក និងម្ចាស់សហគ្រាសចាស់។[56]

---

[54] មាត្រា ១៣៦ នៃច្បាប់ភូមិបាល ២០០១

[55] មាត្រា ៥៨៩ នៃក្រមរដ្ឋប្បវេណី ២០០៧

[56] មាត្រា ៨៧ នៃច្បាប់ស្តីពីការងារ ឆ្នាំ១៩៩៧

# ជំពូកទី៣
# ការរំលាយកិច្ចសន្យា

## ផ្នែកទី១ ប្រភពនៃសិទ្ធិរំលាយកិច្ចសន្យា

ការរំលាយកិច្ចស្យាសំដៅទៅលើសកម្មភាពឯកតោភាគីដែលធ្វើឱ្យភាគីទាំងសងខាងរួចផុតពីករណីកិច្ចរបស់ខ្លួននៅក្នុងកិច្ចសន្យាលើកលែងតែករណីយកិច្ចសងការខូចខាត ។[57] ការរំលាយកិច្ចសន្យា គឺជាសកម្មភាពឯកតោភាគី ដូច្នេះមិនចាំបាច់មានការព្រមព្រៀងពីភាគីម្ខាងទៀតទេ។ សិទ្ធិរំលាយកិច្ចសន្យាមានប្រភពមួយចំនួនដូចជាៈ

សិទ្ធិរំលាយកិច្ចសន្យា ដែលបានកំណត់នៅក្នុងច្បាប់សិទ្ធិរំលាយកិច្ចសន្យា ដែលបានកំណត់នៅកិច្ចសន្យាសិទ្ធិរំលាយកិច្ចសន្យាដែលផ្អែកលើបញ្ញត្តិពិសេស។

### ១.១. សិទ្ធិរំលាយកិច្ចសន្យា ដែលបានកំណត់នៅក្នុងច្បាប់

សិទ្ធិរំលាយកិច្ចសន្យា ដែលបានកំណត់ក្នុងច្បាប់ត្រូវបានចែងពី មាត្រា ៤០៧ ដល់ មាត្រា ៤១៣។ ឧទាហរណ៍៖ ក បានទិញរថយន្តពី ខ ដោយ ក បានបង់ប្រាក់រួចរាល់ហើយ តែដល់ថ្ងៃប្រគល់រថយន្ត ខ មិនបានប្រគល់ទេ បន្ទាប់មក ក បានដាស់តឿនដោយ កំណត់អំឡុងពេលសមរម្យ តែនៅពេលអំឡុងពេលសមរម្យបានកន្លងហួសហើយ ខ នៅតែមិនបានប្រគល់រថយន្តឱ្យ ក ទៀតក្នុងករណីនេះ ក មានសិទ្ធិរំលាយកិច្ចសន្យា។[58]

### ១.២. សិទ្ធិរំលាយកិច្ចសន្យា ដែលបានកំណត់នៅក្នុងកិច្ចសន្យា

សិទ្ធិរំលាយកិច្ចសន្យា ដែលបានកំណត់នៅក្នុងកិច្ចសន្យា គឺជាសិទ្ធិរំលាយកិច្ចសន្យា ដែល ភាគីម្ខាង ឬសងខាងអាចរំលាយកិច្ចសន្យាបាន ដោយយោងទៅលើកិច្ចសន្យានោះតែម្តង។ មានន័យថា ពេលធ្វើកិច្ចសន្យាភាគីនៃកិច្ចសន្យាបានចែងពីសិទ្ធិរំលាយកិច្ចសន្យានៅក្នុងកិច្ចសន្យាតែម្តង។[59]

ឧទាហរណ៍៖ ចំពោះការទិញលក់ម៉ូតូ ដែលអាចឱ្យអ្នកទិញប្រើសាកល្បង។ ប្រសិនបើកិច្ចសន្យាបានចែងថា អ្នកទិញមានសិទ្ធិរំលាយកិច្ចសន្យាលក់ទិញម៉ូតូក្នុងអំឡុងពេល ២សប្តាហ៍ ក្រោយពីទទួលម៉ូតូ។ ដូច្នេះអ្នកទិញអាចរំលាយកិច្ចសន្យាបានតាមលក្ខខណ្ឌដែលមានចែងក្នុងកិច្ចសន្យានោះផ្ទាល់តែម្តង។

### ១.៣. សិទ្ធិរំលាយកិច្ចសន្យា ដែលផ្អែកលើបញ្ញត្តិពិសេស

សិទ្ធិរំលាយកិច្ចសន្យា មានចែងនៅក្នុងកិច្ចសន្យាពិសេសតែម្តង។ ឧទាហរណ៍៖ មាត្រា ៦៤៧ ទាក់ទងនឹងការរំលាយកិច្ចសន្យាអាណត្តិបានចែងថា ភាគីនីមួយៗអាចរំលាយកិច្ចសន្យាអាណត្តិនៅពេលណាក៏បាន។ មាត្រា៦៦៣ ទាក់ទងនឹងការរំលាយកិច្ចសន្យាម៉ៅការបានចែងថា ម្ចាស់ការអាចរំលាយកិច្ចសន្យា នៅពេលណាក៏បានដោយសងសំណងនៃការខូចខាតរហូតដល់ពេលដែលអ្នកម៉ៅការបានសម្រេចការងារ។ ការរំលាយកិច្ច

---

[57] មាត្រា ៤១១ នៃក្រមរដ្ឋប្បវេណី

[58] មាត្រា ៤០៨ (ក) នៃក្រមរដ្ឋប្បវេណី

[59] ច្បាប់កិច្ចសន្យា (មេធាវី ជ្រា ឈុនឡេង) ទំព័រ៩១

សន្យាដែល ផ្អែកលើបញ្ញាត្តិពិសេសនេះនឹងត្រូវបានលើកយកមកសិក្សាលម្អិតនៅពេលសិក្សាពីកិច្ចសន្យាសំខាន់ៗនោះតែម្តង។[60]

### ១.៤. ប្រព័ន្ធប្រហាក់ប្រហែលនឹងការរំលាយកិច្ចសន្យា

ប្រព័ន្ធមួយចំនួនដែលមាន លក្ខណៈប្រហាក់ប្រហែលទៅនឹងការរំលាយកិច្ចសន្យាក៏ប៉ុន្តែវាមិនមែនជាការរំលាយកិច្ចសន្យាទេ។

#### ១.៤.១. ការរំលាយកិច្ចសន្យាដោយការព្រមព្រៀង

ការរំលាយកិច្ចសន្យាដោយការព្រមព្រៀងមានន័យថា ការរំលាយកិច្ចសន្យាដោយផ្អែកទៅលើ ការព្រមព្រៀងថ្មីរបស់គូភាគីនៅក្នុងករណីដែលគូភាគីមិនបានចែងអំពីការរំលាយកិច្ចសន្យានោះ នៅក្នុងកិច្ចសន្យារបស់ខ្លួន។

ឧទាហរណ៍៖ ក បានលក់រថយន្តឱ្យទៅ ខ តែបន្ទាប់មក ខ បានជួបបញ្ហាសេដ្ឋកិច្ចដែលធ្វើឱ្យ ខ មិនមានប្រាក់គ្រប់គ្រាន់ដើម្បីប្រគល់ឱ្យ ក ហើយ ខ ក៏បានសុំ ក ដើម្បីរំលាយកិច្ចសន្យានោះចោល ដោយសារការអាណិត ក បានយល់ព្រម។ នៅក្នុងករណីនេះ ភាគីទាំងពីរបានព្រមព្រៀងគ្នាដើម្បីបង្កើតកិច្ចសន្យាថ្មីដើម្បីរំលាយកិច្ចសន្យាចាស់ចោល។ ការរំលាយដោយការព្រមព្រៀងនេះ មានភាពខុសពីការរំលាយកិច្ចសន្យាដែលបានកំណត់នៅក្នុងច្បាប់ដោយភាគីដែលចង់រំលាយកិច្ចសន្យាមិនអាចបង្ហាញឆន្ទៈឯកតោភាគីឡើយ ដាច់ខាតត្រូវតែមានការយល់ព្រមពីភាគីម្ខាងទៀតនៃកិច្ចសន្យា។ ហើយវាក៏មានលក្ខណៈខុសពីការរំលាយកិច្ចសន្យាដែលបានកំណត់នៅក្នុងកិច្ចសន្យា ដែលត្រូវអនុវត្តដោយផ្អែកលើលក្ខខណ្ឌដែលបានកំណត់នៅក្នុងកិច្ចសន្យាផងដែរ។

### ១.៥. លក្ខខណ្ឌនៃការរំលាយកិច្ចសន្យា

ភាគីម្ខាងនៃកិច្ចសន្យាអញ្ញមញ្ញ អាចរំលាយកិច្ចសន្យាបានភ្លាមៗ ក្នុងករណីដែលភាគីម្ខាងទៀតបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ។[61] ជាសរុបមកលក្ខខណ្ឌនៃការរំលាយកិច្ចសន្យាដោយមូលហេតុមិនអនុវត្តកាតព្វកិច្ចមានចំនួន២គឺៈ ក្នុងកិច្ចសន្យាទ្វេភាគី ភាគីម្ខាងបានបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ។ យោងតាមមាត្រា ៤០៨ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី ភាគីដែលបំពានកិច្ចសន្យា មិនអាចរារាំងការរំលាយកិច្ចសន្យាដោយយកមូលហេតុថា ខ្លួនគ្មានកំហុសចំពោះការមិនអនុវត្តកាតព្វកិច្ចរបស់ខ្លួនបានឡើយ។ ដូច្នេះ មានភាពខុសគ្នា ពីករណីនៃសំណងនៃការខូចខាតដោយការរំលាយកិច្ចសន្យា ដែលមិនតម្រូវឱ្យមានកំហុសរបស់កូនបំណុលទេ។ យោងតាមមាត្រា ៤០៨ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណី ការបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរសំដៅទៅលើករណីដែលភាគីម្ខាងមិនអាចសម្រេចគោលបំណងនៃកិច្ចសន្យាបាន ដោយសារការបំពានរបស់ភាគីម្ខាងទៀត។ ត្រូវចាត់ទុកថាមាន ការបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ ក្នុងករណីដូចខាងក្រោមនេះគឺការយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ចអលទ្ធភាពក្នុងការអនុវត្តកាតព្វកិច្ចចំពោះពេលវេលាអលទ្ធភាពក្នុងការអនុវត្តកាតព្វកិច្ច ការបាត់បង់ទំនុកចិត្ត

[60] ច្បាប់កិច្ចសន្យា (មេធាវី ជ្រា ឈុនឡេង) ទំព័រ៩២

[61] មាត្រា ៤០៧ នៃក្រមរដ្ឋប្បវេណី

រវាងភាគីចំណុចផ្សេងក្រៅពីការបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរទាំង៤ ចំណុចខាងលើនេះ តុលាការអាចទទួលស្គាល់ថាមានការបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរដែរអាស្រ័យទៅតាមស្ថានការណ៍ជាក់ស្តែង។

### ១.៥.១. ការយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ច

ភាគីម្ខាងបានដាស់តឿនភាគីម្ខាងទៀតដែលមិនបានអនុវត្តកាតព្វកិច្ច តាមពេលកំណត់ដោយកំណត់អំឡុងពេលសមរម្យដើម្បីអនុវត្តកាតព្វកិច្ចហើយកាតព្វកិច្ចមិនត្រូវបានអនុវត្តក្នុងអំឡុងពេលនោះ។[62] ជាសរុបមក ការយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ច មានលក្ខខណ្ឌចំនួន៣គឺៈ

- កូនបំណុលមិនអនុវត្តកាតព្វកិច្ចរបស់ខ្លួន តាមពេលកំណត់
- ម្ចាស់បំណុលដាស់តឿនកូនបំណុលដែលមិនអនុវត្តកាតព្វកិច្ចឱ្យអនុវត្តក្នុងអំឡុងពេលសមរម្យ។
- កូនបំណុលមិនអនុវត្តកាតព្វកិច្ចនៅក្នុងអំឡុងពេលសមរម្យ។

ឧទាហរណ៍៖ ក បានទិញរថយន្តពី ខ ដោយ ខ បានប្រគល់រថយន្តឱ្យ ក រួចរាល់ហើយ ប៉ុន្តែ ក មិនទាន់បានប្រគល់ប្រាក់ឱ្យ ខ នៅពេលកំណត់ទេ បន្ទាប់មកទៀត ខ បានកំណត់អំឡុងពេលសមរម្យដើម្បីឱ្យ ក ប្រគល់ប្រាក់តែ ក នៅតែមិនបានប្រគល់ប្រាក់ឱ្យ ខ ដដែល។ នៅក្នុងករណីនេះ ខ ដដែល។ នៅក្នុងករណីនេះ ខ អាចរំលាយកិច្ចសន្យាបានដោយហេតុថា ក មានការយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ច។

### ១.៥.២. អលទ្ធភាពក្នុងការអនុវត្តកាតព្វកិច្ចដែលមានពេលកំណត់

ភាគីមិនបានអនុវត្តកាតព្វកិច្ចតាមពេលកំណត់ក្នុងកិច្ចសន្យាក្នុងករណីដែលគោលបំណងនៃកិច្ចសន្យាមិនបានសម្រេចសោះ បើភាគីមិនអនុវត្តកាតព្វកិច្ចតាមពេលកំណត់នោះ។[63] ឧទាហរណ៍៖ ក បានទៅកាត់សម្លៀកបំពាក់សម្រាប់ពិធីអាពាហ៍ពិពាហ៍របស់ខ្លួនដោយ កំណត់យកមុនថ្ងៃ អាពាហ៍ពិពាហ៍របស់ខ្លួនមួយថ្ងៃគឺនៅថ្ងៃទី២០ ខែមេសា ឆ្នាំ២០១៥ ប៉ុន្តែជាងកាត់ដេរសម្លៀកបំពាក់ខកខានមិនបានធ្វើតាមពេលកំណត់។ ក្នុងករណី នេះ ក មានសិទ្ធិរំលាយកិច្ចសន្យាបានដោយហេតុថា ក គ្មានអត្ថប្រយោជន៍ក្នុងការទទួលយកការអនុវត្តកាតព្វកិច្ចនៅក្រោយពេលអាពាហ៍ពិពាហ៍នោះទេ។

### ១.៥.៣. អលទ្ធភាពក្នុងការអនុវត្តកាតព្វកិច្ច

ភាគីមិនអាចអនុវត្តករណីយកិច្ច ផ្តល់តាវកាលិកចម្បងរបស់ខ្លួនបានទេ។[64] តាវកាលិកចម្បងគឺជាសកម្មភាពដែលភាគីមិនអាចសម្រេចគោលបំណងនៃកិច្ចសន្យា ប្រសិនបើតាវកាលិកនោះមិនត្រូវបានផ្តល់ឱ្យ។ តាវកាលិកចម្បងត្រូវសម្រេចដោយផ្អែកលើលក្ខណៈ ឬខ្លឹមសារនៃកិច្ចសន្យា និងឆន្ទៈរបស់គូភាគី។ឧទាហរណ៍៖ ក បានទិញរថយន្តពី ខ ដោយប្រគល់ប្រាក់រួចរាល់ហើយ ក៏ប៉ុន្តែនៅមុនពេលប្រគល់រថយន្តនោះមានទឹកជំនន់បានធ្វើឱ្យខូចម៉ាស៊ីនរបស់រថយន្ត។ នៅក្នុងករណីនេះ ទោះបីជារថយន្តស្ថិតនៅក្នុងសភាពដើមក៏ដោយ ក៏កាតព្វកិច្ចក្លាយជាអលទ្ធភាពដែរពីព្រោះ ក មិនអាចប្រើរថយន្តដែលខូចម៉ាស៊ីននោះទេ។ ដូច្នេះ ក អាចរំលាយកិច្ចសន្យាលក់ទិញនោះបាន ដោយហេតុថា ខ មិនអាចប្រគល់រថយន្តដែលជាតាវកាលិកចម្បងនៃកិច្ចសន្យា។

---

[62] មាត្រា ៤០៨ (១-ក) នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[63] មាត្រា ៤០៨ (១-ខ) នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[64] មាត្រា ៤០៨ (១-គ) នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

នៅក្នុងករណីដែលមានតាវកាលិកបន្ទាប់បន្សំរួមជាមួយតាវកាលិកចម្បង នោះម្ចាស់បំណុលមិនអាចរំលាយកិច្ចសន្យា ដោយសារតែកូនបំណុលមិនអនុវត្តកាតព្វកិច្ចបន្ទាប់បន្សំនោះទេ។

ឧទាហរណ៍ ក បានទិញទូរទស្សន៍ពី ខ ដោយ ក បានប្រគល់ប្រាក់រួចរាល់ហើយ ចំណែកឯ ខ ក៏បានប្រគល់ទូរទស្សន៍ហើយផងដែរតែ ខ មិនបានប្រគល់ប្រដាប់បញ្ជាទូរទស្សន៍ទេ។ នៅក្នុងករណីនេះ ប្រដាប់បញ្ជាទូរទស្សន៍គឺជាការតព្វកិច្ចបន្ទាប់បន្សំដូច្នេះ ក មិនអាចរំលាយកិច្ចសន្យានេះបានទេ ដោយផ្អែកលើមូលហេតុមិនអនុវត្តកាតព្វកិច្ច។

#### ១.៥.៤. ការបាត់បង់ទំនុកចិត្តរវាងភាគី

ការបំពានកិច្ចសន្យាមានភាពហួសហេតុដែលធ្វើឱ្យបាត់បង់នូវទំនុកចិត្តរវាងគូភាគី ហើយមិនអាចជឿជាក់ថានឹងអនុវត្តកាតព្វកិច្ចនាអនាគតបាន។[65]ចំពោះការរំលាយកិច្ចសន្យាប្រភេទនេះ មានភាពមិនច្បាស់លាស់ទេ។ ទំនុកចិត្តរវាងគូភាគីចាំបាច់មានខ្លាំងនៅក្នុងកិច្ចសន្យាមួយចំនួនដូចជា កិច្ចសន្យាលក់ទិញបន្តបន្ទាប់កិច្ចសន្យាម៉ៅការ កិច្ចសន្យាជួល ជាអាទិ៍ ដែលជាប្រភេទកិច្ចសន្យាដែលគូភាគីត្រូវអនុវត្តកាតព្វកិច្ចជាបន្តបន្ទាប់ក្នុងអំឡុងពេលវែង។

ឧទាហរណ៍៖ ក ជាអ្នកលក់ទឹកអំពៅ ដែលទិញអំពី ខ ដោយគូភាគីទាំងពីរព្រមព្រៀងគ្នាថា ខ ត្រូវតែប្រគល់អំពៅ ឱ្យ ក ក្នុងមួយសប្តាហ៍ម្តងរាល់ព្រឹកថ្ងៃអាទិត្យម៉ោង៧។ ជារឿយៗ ខ ប្រគល់អំពៅយឺត ២ ទៅ ៣ម៉ោង ដែលជាហេតុធ្វើឱ្យកមិនបានលក់ក្នុងអំឡុងពេលយឺតនោះជាញឹកញាប់ផងដែរ។ វាជាការលំបាកដែល ក អាចរក្សាទំនុកចិត្តជាមួយ ខ ទោះបីជាការយឺតម្តងៗមិនមានលក្ខណៈធ្ងន់ធ្ងរក៏ដោយ។ ដូច្នេះ ក អាចរំលាយកិច្ចសន្យាដោយសារការបាត់បង់ទំនុកចិត្តទៅលើ ខ។

### ១.៦ វិធីអនុវត្តសិទ្ធិរំលាយកិច្ចសន្យា

-ភាគីម្ខាងដែលមានសិទ្ធិរំលាយអាចរំលាយកិច្ចសន្យាបាន ដោយបង្ហាញឆន្ទៈរំលាយចំពោះភាគីម្ខាងទៀតបាន។ ការបង្ហាញឆន្ទៈរំលាយនេះអាចធ្វើឡើងក្រៅតុលាការបាន។[66]

ការបង្ហាញឆន្ទៈរំលាយនេះអាចធ្វើឡើងក្រៅតុលាការបាន ដោយហេតុថាវាធ្វើឱ្យមានបន្ទុក កាន់តែធ្ងន់សម្រាប់តុលាការ និងជាការលំបាកសម្រាប់គូភាគីដែលត្រូវសុំឱ្យតុលាការចេញសេចក្តីសម្រេចនៅគ្រប់ពេលដែលភាគីម្ខាងមានបំណងរំលាយកិច្ចសន្យាម្យ៉ាងវិញទៀត ប្រសិនបើភាគីម្ខាងមិនព្រមទទួលការរំលាយកិច្ចសន្យានោះ ភាគីដែលបានរំលាយកិច្ចសន្យានោះ នឹងប្តឹងទៅតុលាការដើម្បីទាមទារសេចក្តីសម្រេច។

-ការបង្ហាញឆន្ទៈរំលាយនេះមិនអាចដកវិញបានទេ។[67]

មិនអនុញ្ញាតឱ្យដកការបង្ហាញឆន្ទៈរំលាយកិច្ចសន្យា ដោយហេតុថា អាចកើតឡើងនូវភាពច្របូកច្របល់ទៅដល់ឋានៈរបស់ភាគីម្ខាងទៀត ឬភាគីដែលមានផលប្រយោជន៍ពាក់ព័ន្ធ នឹងក្លាយជាអស្ថិរភាព។ ប៉ុន្តែជនដែលមានសិទ្ធិរំលាយអាចដកនូវឆន្ទៈរំលាយកិច្ចសន្យបាននៅពេលដែល ការជូនដំណឹងពីការដកឆន្ទៈបាន

---

[65] មាត្រា ៤០៨ (១-ឃ) នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[66]មាត្រា ៤០៩ (១-ក) នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[67] មាត្រា ៤០៩ (១-ខ) នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ដល់ភាគីម្ខាងទៀតនៅពេលព្រមគ្នា ឬមុនពេលឆន្ទៈរំលាយពីព្រោះការរំលាយមានអានុភាពនៅពេលដែលវាបានទៅដល់ភាគីម្ខាងទៀត។

-ការបង្ហាញឆន្ទៈរំលាយនេះ អាចដាក់លក្ខខណ្ឌបង្អង់បាន។[68]

លក្ខខណ្ឌសំដៅទៅលើព្រឹត្តិការណ៍ដែលកើតឡើង នាពេលអនាគតហើយដែលមិនទៀងទាត់។ ទន្ទឹមនឹងនោះ លក្ខខណ្ឌបង្អង់មានន័យថា កាតព្វកិច្ចឬសិទ្ធិនឹងមានអានុភាពនៅពេលដែលលក្ខខណ្ឌបានបំពេញ។ ឧទាហរណ៍៖ ក បានទិញកុំព្យូទ័រមួយគ្រឿងពី ខ ហើយ ក មិនបានបង់ប្រាក់គ្រប់គ្រាន់នៅកាលបរិច្ឆេទប្រគល់នោះទេ បន្ទាប់មក ខ បានប្រាប់ ក ថា គាត់នឹងរំលាយកិច្ចសន្យានៅពេលដែល ក មិនបានបង់ប្រាក់គ្រប់គ្រាន់ក្នុងរយៈពេល១សប្ដាហ៍។ ដូច្នេះ ឆន្ទៈនៃការរំលាយនេះត្រូវបានដាក់លក្ខខណ្ឌបង្អង់មួយសប្ដាហ៍។

## ផ្នែកទី២ អានុភាពនៃការរំលាយកិច្ចសន្យា

ចំពោះអានុភាពនៃការរំលាយកិច្ចសន្យា គឺជាបញ្ហានៃការទទួលស្គាល់ ឬមិនទទួលស្គាល់នូវអានុភាពប្រតិសកម្ម។ គំនិតដែលទទួលស្គាល់អានុភាពប្រតិសកម្ម គឺនៅក្នុងករណីដែលកិច្ចសន្យាត្រូវបានរំលាយវាត្រូវចាត់ទុកថា គ្មានកិច្ចសន្យាតាំងពីដំបូង។[69] ដូច្នេះប្រសិនបើភាគីបានទទួលតាវកាលិកនៅមុនពេលរំលាយ គាត់ត្រូវធ្វើបដិទានឡើងវិញនូវស្ថានភាពដើមរបស់ភាគីម្ខាងទៀត ដោយផ្អែកលើសេចក្តីចម្រើនដោយឥតហេតុ។ នៅក្នុងករណីសេចក្តីចម្រើនដោយឥតហេតុកាតព្វកិច្ចត្រូវសង ជាទូទៅ ត្រូវបានកម្រិតត្រឹមផលប្រយោជន៍ដែលមាន ( មាត្រា៧៣៦)។

ឧទាហរណ៍៖ ក បានទិញអំបិលពី ខែ ១០ គីឡូក្រាមដែលមួយគីឡូមានតម្លៃ ១$ ដោយ ក បានទទួលអំបិល ហើយបានឱ្យលុយទៅ ខ ៥$។ ប៉ុន្តែ ក មិនបានបង់ប្រាក់ ៥$ទៀតទេ ទោះបីជា ខ បានដាស់តឿន ហើយបានកំណត់ពេលសមរម្យដើម្បីឱ្យ ក បង់ប្រាក់ក៏ដោយ ហើយ ក បានប្រើប្រាស់អំបិលអស់ ៤គីឡូទៅហើយ។ ក្នុងករណីនេះ ខ អាចរំលាយកិច្ចសន្យា ដូច្នេះ ភាគីទាំងសងខាងត្រូវធ្វើបដិទាន ឡើងវិញនូវស្ថានភាពដើម ដោយផ្អែកលើសេចក្តីសម្រើនដោយឥតហេតុ។ ខ ត្រូវប្រគល់ប្រាក់ ៥$ឱ្យទៅ ក ដូចគ្នាដែរ ក ត្រូវប្រគល់អំបិល ១០គីឡូឱ្យ ខ វិញ ក៏ប៉ុន្តែ ក ប្រើប្រាស់អំបិលអស់ ៤គីឡូ ដូច្នេះ ក ត្រូវសងមកវិញនូវអំបិល ៤ គីឡូដែលបានប្រើអស់ ឬត្រូវសងជាប្រាក់ ៤$ ដែលមានតម្លៃស្មើនឹងអំបិលនោះ។

ឧទាហរណ៍៖ ក បានលក់រថយន្តឱ្យទៅ ខ ដោយប្រគល់រថយន្តរួចរាល់ហើយតែ ខ មិនបានប្រគល់ប្រាក់ឱ្យ ក ទេ ទោះបីជាមានការដាស់តឿនយ៉ាងណាក៏ដោយហើយ ក ក៏បានរំលាយកិច្ចសន្យា។ ដូច្នេះអ្នកទិញ ខ មិនមែនជាកម្មសិទ្ធិករតាំងពីដំបូង ដោយសារការរំលាយកិច្ចសន្យា។ វាមានន័យថា ក ត្រូវចាត់ទុកថា ជាកម្មសិទ្ធិករតាំងពីដំបូង។ ដូច្នេះ ក អាចទាមទារឱ្យប្រគល់រថយន្តមកវិញដោយផ្អែកលើកម្មសិទ្ធិប្រសិនបើ ខ កាន់កាប់រថយន្តនោះ។

[68] មាត្រា ៤០៩ (១-គ) នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[69] ច្បាប់កិច្ចសន្យា (មេធាវី ជ្រា ឈុនឡេ) ទំព័រ៩៩

គំនិតដែលមិនទទួលស្គាល់អានុភាពប្រតិសកម្ម គឺក្នុងករណីដែលកិច្ចសន្យាត្រូវបានរំលាយត្រូវចាត់ទុកថាគ្មានអានុភាពប្រតិសកម្ម។ ដូច្នេះសិទ្ធិលើបំណុលនិងកាតព្វកិច្ចដើមត្រូវផ្លាស់ប្តូរទៅជា សិទ្ធិទាមទារ និងកាតព្វកិច្ចធ្វើបដិទានទៅស្ថានភាពដើមរបស់ភាគី។ នៅក្នុងគំនិតនេះ បញ្ញត្តិនៃការរំលាយកិច្ចសន្យា ត្រូវយកមកអនុវត្តចំពោះពេលអនាគត ហើយទាក់ទងនឹងកាតព្វកិច្ច ដែលមិនទាន់ត្រូវបានអនុវត្ត គឺមិនមានអត្ថិភាពទៀតទេនៅពេលអនាគត។ ផ្ទុយទៅវិញ កាតព្វកិច្ចដែលបានអនុវត្តរួចហើយ គឺមានសុពលភាព ហើយមិនអាចក្លាយជាសេចក្តីចម្រើនឥតហេតុទេ។

ឧទាហរណ៍៖ ក បានលក់រថយន្តឱ្យទៅ ខ ដោយប្រគល់រថយន្តរួចរាល់ហើយ តែ ខ មិនបានប្រគល់ប្រាក់ឱ្យ ក ទេ ទោះបីជាមានការដាស់តឿនយ៉ាងណាក៏ដោយហើយ ក ក៏បានរំលាយកិច្ចសន្យា។ ក បានរំលាយកិច្ចសន្យានោះមិនត្រូវចាត់ទុកថា ខ គ្មានកម្មសិទ្ធិតាំងពីដំបូងឡើយ ប៉ុន្តែនៅពេលដែល ក រំលាយកិច្ចសន្យា ខ ត្រូវប្រគល់រថយន្តទៅឱ្យ ក វិញដែលជាកាតព្វកិច្ចថ្មីដោយផ្អែកលើការរំលាយកិច្ចសន្យា។ យោងតាមមាត្រា ៤១១ នៃក្រមរដ្ឋប្បវេណី អានុភាព ដែលកើតចេញពីការរំលាយកិច្ចសន្យា មានដូចខាងក្រោមៈ

ការរំលាយកិច្ចសន្យានាំឱ្យគូភាគីរួចផុតពីករណីយកិច្ចក្នុងកិច្ចសន្យាលើកលែងតែ ករណីកិច្ចសងការខូចខាត។

ភាគីដែលបានទទួលតាវកាលិក នៃកិច្ចសន្យាតែមួយភាគឬទាំងអស់ត្រូវមានករណីយកិច្ចសងតាវកាលិកនោះទៅភាគីម្ខាងទៀត ដើម្បីឱ្យភាគីនោះទទួលបដិទានឡើងវិញដោយសារការរំលាយ។ ក្នុងករណីដែលភាគីទាំងសងខាង មានករណីយកិច្ចធ្វើបដិទានទៅវិញទៅមកមានករណីយកិច្ចធ្វើបដិទានទៅវិញទៅមក ករណីកិច្ចទាំងនោះត្រូវអនុវត្តនៅពេលជាមួយគ្នា។

ភាគីដែលមានករណីដោយកិច្ចសងជាប្រាក់ដោយសាររំលាយកិច្ចសន្យាត្រូវសងជាមួយនឹងការប្រាក់ដោយគិតចាប់ពីថ្ងៃដែលបានទទួលប្រាក់ដើមនោះ។ ភាគីដែលមានករណីយកិច្ចបង្វិលវត្ថុ ឬជាតាវកាលិកផ្សេងដែលខ្លួនបានទទួលទៅភាគីម្ខាងទៀតដោយសាររំលាយត្រូវសងទាំងផលដែលបានទទួលពីវត្ថុ ឬតាវកាលិកនោះផងដែរ។

-ការរំលាយកិច្ចសន្យា មិនអាចធ្វើឱ្យខូចផលប្រយោជន៍ត្រឹមត្រូវរបស់តតិយជនបានឡើង។

## ២.១. ការរលត់នូវករណីយកិច្ចក្នុងកិច្ចសន្យា

ប្រសិនបើកិច្ចសន្យាមួយត្រូវបានរំលាយចំណងកិច្ចសន្យានឹងត្រូវរលត់។[70] ការរំលាយកិច្ចសន្យានឹងរំលត់រាល់កាតព្វកិច្ចទាំងឡាយរបស់ភាគីដែលកើតឡើងដោយកិច្ចសន្យា និងនាំឱ្យគូភាគីនៃកិច្ចសន្យារួចផុតពីកិច្ចសន្យានោះ។

ប៉ុន្តែក្នុងករណីដែលកិច្ចសន្យា ត្រូវបានរំលាយដោយមូលហេតុមិនអនុវត្តកាតព្វកិច្ចនោះ ករណីយកិច្ចសងសំណងការខូចខាតរបស់កូនបំណុលដែលមិនអនុវត្តកាតព្វកិច្ចនៅតែមានអានុភាព។

[70] ច្បាប់កិច្ចសន្យា (មេធាវី ជ្រា ឈុនឡេង) ទំព័រ១០២

## ២.២. ករណីយកិច្ចធ្វើបដិទានឱ្យគ្នាទៅវិញទៅមក

ក្រោយពីការរំលាយកិច្ចសន្យា ភាគីដែលបានទទួលតាវកាលិកត្រូវសងនូវតាវកាលិកនោះ ទៅឱ្យភាគីម្ខាងទៀតវិញ។ ក្នុងករណីដែលភាគីទាំងសងខាងមានករណីយកិច្ចធ្វើកិច្ចបដិទានទៅវិញទៅមក ករណីយកិច្ចទាំងនោះត្រូវអនុវត្តនៅពេលជាមួយគ្នា។[71]

ឧទាហរណ៍៖ ក បានទិញម៉ូតូរបស់ ខ ដោយបានទទួលម៉ូតូនោះហើយតែ ខ បានទទួលប្រាក់តែពាក់កណ្តាល។ដល់ថ្ងៃប្រគល់ប្រាក់ ក នៅតែមិនបានប្រគល់ប្រាក់ពាក់កណ្តាលទៀត ឱ្យ ខ ទោះបីជាមានការដាស់តឿនយ៉ាងណាក៏ដោយ។ ក្នុងករណីនេះ ខ មានសិទ្ធិរំលាយកិច្ចសន្យាហើយទាមទារ ម៉ូតូរបស់ខ្លួនមកវិញ តែត្រូវប្រគល់ប្រាក់ពាក់កណ្តាល់ដែលខ្លួនបានទទួលឱ្យទៅ ក វិញ។

## ២.៣. ទំហំនៃករណីយកិច្ចធ្វើបដិទាន

ក្រៅពីតាវកាលិកជាប្រាក់ ដែលខ្លួនបានទទួលភាគីត្រូវសងទៅវិញទៅមកផងដែរ នូវការប្រាក់នៃប្រាក់ដែលបានទទួល និងផលប្រយោជន៍ទាំងឡាយបានមកពីការប្រើប្រាស់តាវកាលិកដែលទទួលបាន។[72]

ឧទាហរណ៍ ក បានទិញម៉ូតូរបស់ ខ ដោយបានទទួលម៉ូតូនោះហើយ តែ ខ បានទទួលប្រាក់តែពាក់កណ្តាល។ ដល់ថ្ងៃប្រគល់ប្រាក់ ក នៅតែមិនបានប្រគល់ប្រាក់ពាក់កណ្តាលទៀតឱ្យ ខ ទោះបីជាមានការដាស់តឿនយ៉ាងណាក៏ដោយ។ ក្នុងករណីនេះ ចំពោះអ្នកលក់ ខ មានសិទ្ធិរំលាយកិច្ចសន្យា ហើយទាមទារម៉ូតូរបស់ខ្លួនមកវិញ រួមជាមួយនឹងទឹកប្រាក់ដែលមានតម្លៃស្មើនឹងថ្លៃជួលម៉ូតូក្នុងរយៈពេលដែល ក បានប្រើប្រាស់ម៉ូតូនេះដែលជាផលប្រយោជន៍បានមកពីវត្ថុនោះ។ ចំពោះអ្នកទិញ ក វិញ មានសិទ្ធិទាមទារប្រាក់ពាក់កណ្តាលរួមជាមួយការប្រាក់គិតចាប់ពីពេលដែលអ្នកលក់ ខ បានទទួលប្រាក់នោះ។

## ២.៤. ការការពារតតិយជន

ការរំលាយកិច្ចសន្យា មិនអាចធ្វើឱ្យខូចផលប្រយោជន៍ត្រឹមត្រូវរបស់តតិយជនបានឡើយ។[73] ចំពោះការការពារតតិយជនគឺអាស្រ័យទៅលើថា តើអានុភាពប្រតិសកម្មត្រូវបានទទួលស្គាល់ ឬមិនទទួលស្គាល់។ ការទទួលស្គាល់ ឬមិនទទួលស្គាល់នូវអានុភាពប្រតិសកម្ម គឺជាបញ្ហាដែលមានលក្ខណៈទ្រឹស្តីស្មុគស្មាញ ដែលត្រូវទុកដោះស្រាយតាមយុត្តិសាស្រ្តនាពេលអនាគតដោយមិនចែងក្នុងក្រមរដ្ឋប្បវេណីទេ។

ឧទាហរណ៍៖ ក បានលក់ដីទៅ ឱ្យ ខ ហើយ ខ បានលក់ដីនេះបន្តទៅឱ្យ គ ។ ក៏ប៉ុន្តែ ខ បានខកខានក្នុងការបង់ថ្លៃទិញដីដែលធ្វើឱ្យ ក រំលាយកិច្ចសន្យា។បញ្ហាកើតឡើងត្រង់ថា អ្នកទិញ ខ បានលក់ដីនេះបន្តឱ្យតតិយជន គ មុនពេលដែលអ្នកលក់ ក បង្ហាញឆន្ទៈរំលាយកិច្ចសន្យា។

ទស្សនៈឱ្យមានអានុភាពប្រតិសកម្មនៃការរំលាយកិច្ចសន្យាអ្នកទិញ ខ មិនមែនជាកម្មសិទ្ធិករនៃដីតាំងពីដំបូងដោយសារការរំលាយ។ ហេតុនេះហើយតតិយជន គ ត្រូវចាត់ទុកថាបានទិញដីពីអ្នកទិញ ខ ដែលមិន

[71] ច្បាប់កិច្ចសន្យា (មេធាវី ជ្រា ឈុនឡេង) ទំព័រ១០២

[72] ច្បាប់កិច្ចសន្យា (មេធាវី ជ្រា ឈុនឡេង) ទំព័រ១០៣

[73] ច្បាប់កិច្ចសន្យា (មេធាវី ជ្រា ឈុនឡេង) ទំព័រ១០៣

មានកម្មសិទ្ធិលើដីនេះដូច្នេះ តតិយជន គ មិនអាចធ្វើលទ្ធកម្មនូវកម្មសិទ្ធិលើដីនេះបានទេ។ ប៉ុន្តែក្នុងករណីដែល តតិយជន គ បានចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិរួចហើយ ប្រសិនបើ តតិយជន គ មិនអាចធ្វើលទ្ធកម្មនូវកម្មសិទ្ធិលើដីនេះ ដោយសារការរំលាយកិច្ចសន្យាដោយអ្នកលក់ ក នោះតតិយជន គ នឹងទទួលការខូចខាតដែលខ្លួនមិនអាចព្យាករទុកជាមុនបានហើយធ្វើឱ្យបាត់បង់ផលប្រយោជន៍យ៉ាងធ្ងន់ធ្ងរដល់តតិយជន គ ដោយធ្វើប្រតិបត្តិការដោយជឿទុកចិត្តលើការចុះបញ្ជីកម្មសិទ្ធិរបស់ ខ ។

ទស្សនៈមិនឱ្យមានអានុភាពប្រតិសកម្មនៃការរំលាយកិច្ចសន្យាទោះបីជាអ្នកលក់ ក រំលាយកិច្ចសន្យាលក់ទិញក៏ដោយ អ្នកទិញ ខ មិនត្រូវចាត់ទុកថាគ្មានកម្មសិទ្ធិលើដីតាំងពីដំបូងទេ ប៉ុន្តែ នៅពេលអ្នកលក់ ក បង្ហាញឆន្ទៈរំលាយកិច្ចសន្យានេះ កម្មសិទ្ធិនឹងត្រូវបង្វិលពីតតិយជន គ មកឱ្យអ្នកលក់ ក វិញ។ ចំពោះការផ្ទេរបង្វិលកម្មសិទ្ធិក្នុងករណីនេះការចុះបញ្ជីគឺជាលក្ខខណ្ឌតតាំងចំពោះអចលនវត្ថុ (មាត្រា ១៣៤ ក្រមរដ្ឋប្បវេណី)។ ហេតុដូច្នេះ ទោះបីជាអ្នកលក់បានទទួលកម្មសិទ្ធិដីពីអ្នកទិញខ ដោយសារការរំលាយកិច្ចសន្យាក៏ដោយ ប្រសិនបើតតិជន គ បានចុះបញ្ជីអំពីការផ្ទេរមុនអ្នកលក់ ក ចុះបញ្ជីអំពីការផ្ទេរបង្វិលនោះ តតិយជន គ នឹងមានអាទិភាពហើយអ្នកលក់ ក មិនអាចទាមទារឱ្យលុបចោលការចុះបញ្ជីរបស់តតិយជន គ បានឡើយ។

សរុបមកទោះបីជាការពន្យល់ខាងលើមានភាពស្មុគស្មាញ ហើយទោះបីជាយកទស្សនៈណាមួយក៏ដោយវាជាការសមស្របក្នុងការការពារតតិយជនដែលបានចុះបញ្ជី និងដែលជាជនសុចរិត និងគ្មានកំហុស។

### ២.៥. ការរលត់នូវសិទ្ធិរំលាយកិច្ចសន្យា

ការរំលត់នូវសិទ្ធិរំលាយកិច្ចសន្យាត្រូវបានបែងចែកជា ៣ គឺ៖

- ការអនុវត្តកាតព្វកិច្ច ឬសំណើផ្តល់ការអនុវត្តកាតព្វកិច្ច
-ការខូចខាតកម្មវត្ថុនៃកិច្ចសន្យាដោយចេតនា
-អាជ្ញាយុកាល។ [74]

#### ២.៥.១. ការអនុវត្តកាតព្វកិច្ច ឬសំណើផ្តល់ការអនុវត្តកាតព្វកិច្ច

យោងតាមមាត្រា ៤០៨ កថាខណ្ឌទី ១ វាក្យខណ្ឌ ក ការយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ចមានលក្ខខណ្ឌចំនួន៣ គឺ៖

-កូនបំណុលមិនអនុវត្តកាតព្វកិច្ចរបស់ខ្លួន តាមពេលកំណត់

-ម្ចាស់បំណុលដាស់តឿនកូនបំណុល ដែលមិនអនុវត្តកាតព្វកិច្ច ឱ្យអនុវត្តក្នុងអំឡុងពេលសមរម្យ។

-កូនបំណុល មិនអនុវត្តកាតព្វកិច្ច នៅក្នុងអំឡុងពេលសមរម្យ។

ដូច្នេះ ប្រសិនបើកូនបំណុលអនុវត្តកាតព្វកិច្ចនៅក្នុងអំឡុងពេលនោះកាតព្វកិច្ច ត្រូវរលត់ដោយសារការសម្រេចនូវគោលបំណងនោះសិទ្ធិរំលាយក៏ត្រូវរលត់ដែរ។ ករណីដែលម្ចាស់បំណុមិនព្រមទទួលយកកម្មវត្ថុ

[74] ច្បាប់កិច្ចសន្យា (មេធាវី ជ្រា ឈុនឡេង) ទំព័រ១០៥

ទោះបីជាកូនបំណុលដោយយោងទៅតាមការដាស់តឿនរបស់ម្ចាស់បំណុលនោះសិទ្ធិរំលាយរបស់ម្ចាស់បំណុល ត្រូវរលត់។

### ២.៥.២. ការខូចខាតកម្មវត្ថុនៃកិច្ចសន្យា

សិទ្ធរំលាយក្នុងករណីដែលកម្មវត្ថុនៃកិច្ចសន្យាត្រូវបានខូចខាត ឬ បាត់បង់។[75]

-បានធ្វើឱ្យមានការខូចខាត ឬបាត់បង់ដល់វត្ថុដែលជាកម្មវត្ថុនៃកិច្ចសន្យា ឬមិនអាចសងវត្ថុ នោះវិញដោយចេតនា។ ឧទាហរណ៍៖ កម្មវត្ថុនៃកិច្ចសន្យាបានលក់បន្ត ឬបានបាក់បែកអស់ ដោយចេតនា។

-ធ្វើឱ្យវត្ថុនោះក្លាយជាវត្ថុផ្សេងដោយការកែច្នៃ ឬការផ្លាស់ទម្រង់ ដោយចេតនា។ ឧទាហរណ៍: ការទិញអង្ករ តែអង្ករត្រូវបានធ្វើជានំបញ្ចុកអស់ទៅហើយ។

ក៏ប៉ុន្តែក្នុងករណីដែលកម្មវត្ថុត្រូវបានធ្វើឱ្យខូចខាត ឬបាត់បង់ ឬមិនអាចសងមកវិញ ដោយមិនមាន ចេតនា នោះសិទ្ធិរំលាយមិនត្រូវរលត់ទេ។ គាត់អាចរំលាយកិច្ចសន្យាបានប៉ុន្តែ គាត់ត្រូវសងជាទឹកប្រាក់ចំពោះ តម្លៃដែលត្រូវបានបន្ថយដោយសារការខូចខាតនោះ។

ឧទាហរណ៍៖ ក បានទិញរថយន្តពី ខ ដែលជារថយន្តថ្មី ហើយភាគីទាំងពីរនាក់បានអនុវត្តកាតព្វកិច្ច រួចរាល់ហើយដោយ ក បានទទួលរថយន្ត និង ខ បានទទួលប្រាក់ តែក្រោយមក ក បានដឹងថារថយន្តនោះមិន មែនជារថយន្តថ្មីទេ ហើយបានទាមទារឱ្យ ខ ប្រគល់រថយន្តថ្មី ដោយកំណត់អំឡុងពេលសមរម្យ តែ ខ នៅតែមិន ព្រមប្រគល់ហេតុនេះហើយបានជា ក រំលាយកិច្ចសន្យាតែមុនពេលប្រគល់រថយន្តនោះ ក បានធ្វើឱ្យខូចខាតរថ យន្តដោយអចេតនា ក្នុងគ្រោះថ្នាក់ចរាចរណ៍មួយ។ ក អាចរំលាយកិច្ចសន្យាបាន តែត្រូវចេញថ្លៃជួសជុលរថយន្ត ដែលខ្លួនបានធ្វើឱ្យខូចខាត។

ករណីប្រធានសក្តិមានន័យថា ជាកម្លាំងដ៏មានឧត្តមភាពជាការកកើតឡើងដោយមិនបានគ្រោងទុក ជាគ្រោះថ្នាក់ដែលមិនអាចបញ្ចៀស ឬតតាំងបាន។ ពាក្យនេះតែងត្រូវបានគេបញ្ចូលក្នុង ខចែងរួមនៃកិច្ចសន្យា ក្នុងបំណងឲ្យគូភាគីកិច្ចសន្យារួមពីការទទួលខុសត្រូវ ឬកាតព្វកិច្ចពេលមានព្រឹត្តការណ៍ឬកាលៈទេសៈពិសេស កើតឡើងដោយគូភាគីនៃកិច្ចសន្យាមិនអាចត្រួតត្រាបានដូចជា៖ សង្គ្រាម ការបះបោរ ទឹកជំនន់រញ្ជួយផែនដី ភ្នំ ភ្លើងផ្ទុះជាដើម។ ឧទាហរណ៍៖ករណីដូចជាការផ្ទុះឡើងនិងឆ្លងជាសកលនៃវិរុសកូវីដ១៩(COVID19) អាចចាត់ ទុកជាវាជាជម្ងឺ/វិរុសមួយដែលផ្ទុះពេញសាកលលោកធ្វើឲ្យអោយឈឺ ស្លាប់ដំណើរការសេដ្ឋកិច្ចគាំង/ធ្លាក់ចុះ មនុស្សមិនអាចប្រកបរបរដូចធម្មតា។

### ២.៥.៣. ការរលត់នូវសិទ្ធរំលាយកិច្ចសន្យាដោយអាជ្ញាយុកាល

អាជ្ញាយុកាលនៃការរំលត់សិទ្ធិរំលាយកិច្ចសន្យា ដោយមូលហេតុនៃការមិនអនុវត្តកាតព្វកិច្ច និងសិទ្ធិ ទាមទារបដិទានមានអំឡុងពេល ៥ឆ្នាំក្រោយពីពេលដែលមិនបាន អនុវត្តកាតព្វកិច្ច។[76]

-ការមិនអនុវត្តកាតព្វកិច្ច ត្រូវបានគិតចាប់ពីពេលដែលមានការយឺតយ៉ាវ។

-ការយឺតយ៉ាវត្រូវបានគិតចាប់ពីពេលដែលភាគីម្ខាងបានអនុវត្តកាតព្វកិច្ចរួចរាល់។

[75] មាត្រា ៤១២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[76] មាត្រា ៤១៣ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ការធ្វើបដិទានឡើងវិញនូវស្ថានភាពដើមដោយផ្អែកលើការរំលាយកិច្ចសន្យា មិនត្រូវធ្វើដាច់ពីការរំលាយកិច្ចសន្យាទេ ហើយភាគីដែលមានសិទ្ធិទាមទារឱ្យធ្វើបដិទានត្រូវអនុវត្តសិទ្ធិនេះ នៅមុនពេលសិទ្ធិរំលាយត្រូវរលត់ ដោយអាជ្ញាយុកាល។[77]

ឧទាហរណ៍៖ ក បាន ទិញរថយន្តមួយពី ខ ដោយ ខ បានប្រគល់រថយន្តឱ្យ ក រួចរាល់ហើយ ក៏ប៉ុន្តែ ក មិនបានប្រគល់ប្រាក់ទេ។ ដូច្នេះ ក ត្រូវស្ថិតក្នុងភាពយឺតយ៉ាវ ចាប់តាំងពីពេលដែល ខ ប្រគល់រថយន្ត។ នៅក្នុងករណីនេះអាជ្ញាយុកាលនៃការរំលត់ត្រូវគិតចាប់ពីពេលដែល ក ស្ថិតនៅក្នុងភាពយឺតយ៉ាវ។ ដូច្នេះ ខ ត្រូវអនុវត្តសិទ្ធិរំលាយកិច្ចសន្យា និងសិទ្ធិទាមទារបដិទានក្នុងអំឡុងពេល ៥ឆ្នាំ ចាប់ពីពេលប្រគល់របស់ ខ។

[77] ច្បាប់កិច្ចសន្យា (មេធាវី ជ្រា ឈុនឡេង) ទំព័រ១០៧

# សេចក្តីសន្និដ្ឋាន និង អនុសាសន៍

សរុបមក យើងខ្ញុំអាចសន្និដ្ឋានថានៅក្នុងទំនាក់ទំនងរដ្ឋប្បវេណីត្រូវបានកំណត់ដោយច្បាប់នៅក្នុងប្រទេសកម្ពុជា។ កិច្ចសន្យាមានច្រើនប្រភេទ ក៏ប៉ុន្តែកិច្ចសន្យានីមួយៗវាផ្អែកទៅលើកម្មវត្ថុនៃកិច្ចសន្យានោះកិច្ចសន្យានីមួយៗមានលក្ខណៈខុសប្លែកពីគ្នាជាច្រើនចំណុច ជាពិសេសគឺលក្ខណៈទម្រង់មួយចំនួន។ ចំពោះលក្ខណៈទម្រង់មួយចំនួន។ ចំពោះលក្ខខណ្ឌគ្រឹះ ថ្វីត្បិតតែកិច្ចសន្យាកើតមានត្រឹម ការព្រមព្រៀងក៏ដោយ ក៏កិច្ចសន្យាមិនអាចបង្កើតឡើងបានដែរ ប្រសិនបើបុគ្គលដែល ជាប្រធាននៃកិច្ចសន្យាជាជនដែលត្រូវបានកម្រិតសមត្ថភាពទទួលសិទ្ធិជាអាទិ៍ជនបរទេសដោយយោងទៅតាមរដ្ឋធម្មនុញ្ញ និងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាក៏ប៉ុន្តែ មានការលើកលែងមួយចំនួនដូចជា អគារសហកម្មសិទ្ធិដែលចាប់ពីជាន់ទី២ ឡើងទៅជនដែលត្រូវបានកម្រិតសមត្ថភាពទទួលបាន សិទ្ធិពោលគឺជនបរទេសមានសិទ្ធិបង្កើតកិច្ចសន្យាលក់ទិញបាន។ ចំណែកឯជនដែលត្រូវបានច្បាប់កម្រិតសមត្ថភាពមួយចំនួនទៀតគឺអនីតិជន ជនដែលនៅក្រោមអាណាព្យាបាលទូទៅ និងជនដែលស្ថិតនៅក្រោមហិតូបត្ថម្ភប៉ុន្តែជនទាំងនេះ អាចធ្វើសកម្មភាពក្នុងការបង្កើតកិច្ចសន្យាបានដែល លុះត្រាតែមានការយល់ព្រមពីអាណាព្យាបាល អាណាព្យាបាលទូទៅ និងហិតូបត្ថកៈទើប គាត់អាធ្វើសកម្មភាពបានដោយស្របច្បាប់ និងធ្វើឲ្យកិច្ចសន្យាមានសុពលភាព។ ដើម្បីបង្កើតកិច្ចសន្យាបាន ហើយស្របទៅនឹងច្បាប់ កិច្ចសន្យានោះត្រូវមានការព្រមព្រៀងរវាងគូភាគីទាំងទាំងពីរដោយសុច្ចរិត នឹងស្មោះត្រង់ ពោលគឺសំណើ និងស្វីការត្រូវគ្នា។

ក្រោយពីបង្កើតកិច្ចសន្យាឡើងហើយភាគីទាំងពីរ បានជាប់នូវចំណងគតិយុត្តរវាងគ្នា គឺបំពេញកាតព្វកិច្ចឲ្យគ្នាទៅវិញទៅមកនិងត្រូវការគោរពតាមគោលការណ៍ភាពស្មោះត្រង់ និងសុចរិត។ ដែលភាគីម្ខាងទទួលបានសិទ្ធិ និងផលប្រយោជន៍ពីកិច្ចសន្យា ហើយភាគីម្ខាងទៀតជាអ្នកទទួលបន្ទុកដើម្បីបំពេញកាតព្វកិច្ចទៅឲ្យភាគីម្ខាងទៀត។ ការបំពេញកាតព្វកិច្ចឲ្យគ្នាទៅវិញទៅមករវាងគូភាគីទាំងពីរ ត្រូវបានកំណត់នៅក្នុងកិច្ចសន្យា ដោយមានចែងអំពីខលក្ខខណ្ឌ នៅក្នុងកិច្ចសន្យានោះ ហើយភាគីទាំងពីរចាប់ផ្តើមអនុវត្តកាតព្វកិច្ចចាប់តាំងពីពេលបង្កើតកិច្ចសន្យានោះឡើង និងមានកំណត់អំពីថិរវេលាដើម្បីបញ្ចប់នូវកិច្ចសន្យានោះនូវកាលបរិច្ឆេទមួយច្បាស់លាស់។ ការរំលាយកិច្ចសន្យាអាចត្រូវបានរំលាយតាមមធ្យាបាយជាច្រើនដែលក្នុងនោះអាចរំលាយតាមរំលាយតាមរយៈការកំណត់ដោយច្បាប់ការរំលាយដែលនៅក្នុងក្រមរដ្ឋប្បវេណីស្តីពីកិច្ចសន្យា និង សិទ្ធិដោយមានការព្រមព្រៀងគ្នារបស់គូភាគី។

- ភាគីម្ខាងបានដាស់តឿងភាគីម្ខាងទៀត ដោយភាគីម្ខាងទៀតមិនបានអនុវត្តកាតព្វកិច្ចតាមកាលកំណត់
- ភាគីមិនអនុវត្តករណីកិច្ចតាមពេលកំណត់នៅក្នុងកិច្ចសន្យា

ការរំលាយកិច្ចសន្យាមិនត្រឹមតែមានអានុភាពចំពោះភាគីប៉ុណ្ណោះទេ ពោលគឺមានអានុភាពចំពោះតតិយជនបានឡើយ ។ នេះគឺជាគោលបំណងក្នុងការពារស្ថិរភាពជំនួញរបស់តតិយជនត្រឹមត្រូវផងដែរ។ មិនមែនតតិយជនដែលមានផលប្រយោជន៍ត្រឹមត្រូវតាមច្បាប់នឹងត្រូវទទួលបាននូវការការពារ ហើយនេះក៏ជាយុទ្ធសាស្ត្ររបស់តុលាការកម្ពុជានាពេលអនាគតផងដែរក្នុងការវិនិច្ឆ័យទៅតាមអង្គហេតុនីមួយៗ។

ជាសេចក្តីសង្ខេប កិច្ចសន្យាគឺជាច្បាប់របស់គូភាគី ឬជាកិច្ចព្រមព្រៀង ឬកុងត្រាណាមួយដែលមានលក្ខណៈចងកាតព្វកិច្ចភាគីត្រូវតែគោរព និងកាតព្វកិច្ចទៅវិញទៅមកក្នុងរយៈនៃកិច្ចសន្យាមានសុពលភាព។ ចំពោះភាគីណាមួយមិនបានគោរពនូវអ្វីដែលខ្លួនបានព្រមព្រៀងគ្នាទេនោះភាគីម្ខាងទៀតអាចធ្វើការទាមទារ និងបង្ខំឲ្យភាគីនោះអនុវត្តតាមខកិច្ចសន្យានៅតុលាការឬស្ថាប័នមានសមត្ថកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ជាចុងក្រោយ ដោយសារតែតម្រូវការរបស់សង្គម និងការដើរទៅមុខដ៏លឿនស្ទើរគ្រប់វិស័យនៅក្នុងប្រទេសយើងរួមមាន វិស័យការងារ វិស័យឧស្សាហកម្ម វិស័យកសិកម្ម ពាណិជ្ជកម្មព្រមទាំងមានការវិនិយោគជាច្រើនក្នុងប្រទេសយើងទាំងក្នុងប្រទេស និងក្រៅប្រទេស ធ្វើឲ្យប្រទេសកម្ពុជាយើងមានការរីកចម្រើនផ្នែកចំណេះដឹងក្នុងការ ការពារផលប្រយោជន៍របស់ខ្លួនពីបុគ្គលឆ្លៀតឱកាស ទើបគេត្រូវបង្កើតកិច្ចសន្យា ដើម្បីចងភាគី យើងខ្ញុំសង្ឃឹមយ៉ាងមុតមាំថា ប្រធានបទស្រាវជ្រាវបញ្ចប់ថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រមួយនេះ នឹងចូលរួមចំណែកដ៏ប្រសើរលើការតាក់តែង ការចងក្រងការស្រាវជ្រាវ និងការវិភាគនាពេលអនាគតនិងការវិភាគនាពេលអនាគតជុំវិញទិដ្ឋភាពគតិយុត្តនៃកិច្ចសន្យា។

# ឯកសារយោង


១.ក្រមរដ្ឋប្បវេណី

២.ក្រមរដ្ឋប្បវេណី ភាគ៣ ឆ្នាំ២០១២

៣.ច្បាប់ស្តីពីសិទ្ធិលើបំណុល

៤.សៀវភៅ ច្បាប់កិច្ចសន្យា ដែលរៀបរៀងដោយមេធាវី ជ្រាវ ឈុនឡេង នៅឆ្នាំ២០១៩

៥.សៀវភៅ ច្បាប់កិច្ចសន្យាពិសេស ដែលរៀបរៀងដោយមេធាវី ជ្រាវ ឈុនឡេង នៅឆ្នាំ២០១៩

៦.ផ្នែកពាណិជ្ជកម្ម ដែលរៀបរៀងដោយមេធា វីគឹម សាន

៧.សៀវភៅ និតីកិច្ចពិសេស ដែលរៀបរៀងដោយលោក យស បានចំរុង និង លោក ខាំ សុមករា ឆ្នាំ២០១៣

៨.អត្ថបទស្តីពីលក្ខខណ្ឌសុពលភាពនិងការរំលាយកិច្ចសន្យា រៀបរៀងដោយលោក ជួប ឋិតបេរឬទ្ធិ

៩.សៀវភៅ អានុភាពនៃកិច្ចសន្យា ដែលរៀបរៀងដោយលោក មួន សៀងលី ឆ្នាំ២០១២

១០.កិច្ចសន្យាពិសេស ដែលរៀបរៀងដោយសាស្រ្តាចារ្យ ឆាយ ហុង (ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូង ខេត្តពោធិ៍សាត់)

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

## លិខិតជូនដំណឹងស្ដីពីការរំលាយកិច្ចសន្យាលក់-ទិញដី

លោក **សុខ សំ** កើតឆ្នាំ១៩៤៧ ជនជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខៈ ០១០៩៥១៦៧៦ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ មានអាសយដ្ឋានបច្ចុប្បន្នស្ថិតនៅផ្ទះលេខ១០ ផ្លូវបេតុង ភូមិពោធិ៍រលំ សង្កាត់សាក់សំពៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ ជាអ្នកលក់ដី និងជា **ភាគី** "ក"។

**សូមជម្រាបមក**

លោក **ហាម រ៉េន** កើតឆ្នាំ១៩៧៩ ជនជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខៈ ០១១៣២៧៣១៩ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៥ និងលោក **ខន ខណ្ណា:** កើតឆ្នាំ១៩៨៤ ជនជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខៈ ០១០៨១៤៣៥០(០១) ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៥ មានអាសយដ្ឋានបច្ចុប្បន្នស្ថិតនៅផ្ទះលេខ ៥៩ ភូមិទួលពង្រ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ជាអ្នកទិញដី និងជា **ភាគី "ខ"** ។

**កម្មវត្ថុ៖** ជូនដំណឹងស្ដីពីការបង្ហាញឆន្ទៈរំលាយកិច្ចសន្យាទិញ-លក់អចលនវត្ថុ(ដី) ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២០ ,កិច្ចសន្យា ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២០,កិច្ចសន្យា ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២០ និងកិច្ចសន្យាបន្ថែម ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២០ ដោយមូលហេតុ **ភាគី "ខ"** បានបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ។

**យោង៖**
- កិច្ចសន្យាទិញ-លក់អចលនវត្ថុ(ដី) ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២០។
- កិច្ចសន្យា ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២០។
- កិច្ចសន្យា ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២០។
- កិច្ចសន្យាបន្ថែម ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២០។

សេចក្ដីដូចបានជម្រាបជូនក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូនលោក **ហាម រ៉េន** និងលោក **ខន ខណ្ណា:** ជ្រាបថា៖ កាលពីថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២០ ខ្ញុំ ហើយនិងលោក បានព្រមព្រៀងគ្នាជាលើចុងក្រោយនៅចំពោះមុខមេធាវីទាំងសងខាង ដោយកំណត់យកថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០២០ ជាលើកចុងក្រោយនៃការប្រគល់-ទទួលប្រាក់ដំណាក់កាលទី៤ ដែលមានទឹកប្រាក់ចំនួន ១៥០.០០០ (ដប់ប្រាំម៉ឺន) ដុល្លារអាមេរិក។ ប៉ុន្តែរហូតមកដល់ពេលនេះ នៅតែពុំឃើញលោកមកអនុវត្តកាតព្វកិច្ចបង់ប្រាក់មកឱ្យខ្ញុំឡើយ យោងតាមកិច្ចសន្យាទិញ-លក់ដីខាងលើ ត្រង់ប្រការ៥ ចំណុច ៥.១ ចំណុច៥.៣ និងយោងតាមកិច្ចសន្យាបន្ថែម ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២០ ត្រង់ចំណុចទី៣ គឺលោកបាន**បំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ** និងធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍របស់ខ្ញុំយ៉ាងខ្លាំងទៀតផង។ ហេតុដូច្នេះខ្ញុំសម្រេចចិត្តបង្ហាញឆន្ទៈរំលាយកិច្ចសន្យាលក់-ទិញដី ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២០, កិច្ចសន្យា ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២០, កិច្ចសន្យា ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២០ និងកិច្ចសន្យាបន្ថែម ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២០ ដែលធ្វើឡើងរវាងលោក និងខ្ញុំ ចាប់ពីពេលនេះតទៅ។ ចំណែកប្រាក់ដែលលោកបានទូទាត់ឱ្យខ្ញុំទាំងអស់កន្លងមក ត្រូវក្លាយជាកម្មសិទ្ធិរបស់ខ្ញុំ ដោយលោកគ្មានសិទ្ធិទាមទារមកវិញឡើយ ហើយខ្ញុំនឹងធ្វើការចូលគ្រប់គ្រង ចាត់ចែងអចលនវត្ថុខាងលើជាម្ចាស់កម្មសិទ្ធិវិញ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមលោកជា**ភាគី "ខ"** ជ្រាបជាព័ត៌មាន។

សូមលោកជា **ភាគី "ខ"** ទទួលនូវការរាប់អានអំពីខ្ញុំ។

ថ្ងៃ [illegible] ខែមិគសិរ ឆ្នាំជូត ទោស័ក ពស ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០២០
ស្នាមមេដៃស្ដាំ

សុខ សំ

**បានឃើញ**
ថ្ងៃ [illegible] ខែមិគសិរ ឆ្នាំជូត ទោស័ក ពស ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែធ្នូ ឆ្នាំ២០២០
ហត្ថលេខា និងត្រា

AVOCAT ATTORNEY AT LAW
KINGDOM OF CAMBODIA

មេធាវី.វ៉ស់_ផល្លា

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

........

<u>លិខិតជូនដំណឹង</u>

ខ្ញុំបាទឈ្មោះ គង់ សុខសាន្ត (ហៅអ៊ី ជួអេ ឬ ចាន់ណា សុភារ៉ា) ភេទប្រុស ឆ្នាំកំណើត ១៩៧១ ជនជាតិខ្មែរ ដែលមានអាសយដ្ឋាន នៅផ្ទះលេខ ១៨១ ផ្លូវលេខ ២BT ក្រុម ទី ១២ ភូមិសន្សំកុសល សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ។

<u>ជម្រាបមក</u>

លោកស្រី យូ ចន្ធា

<u>កម្មវត្ថុ:</u> ស្តីអំពីការរំលាយកិច្ចសន្យាចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៤ និងលិខិតផ្ទេរសិទ្ធិ ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៤ ចាប់ពីថ្ងៃជូនដំណឹងនេះតទៅ។

<u>យោង:</u> -កិច្ចសន្យា ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៤ និងលិខិតផ្ទេរសិទ្ធិ ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៤។

-ដីកាបញ្ជាឱ្យចូលខ្លួនលេខ ០១១ អយ ច/២០ ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២០ របស់អយ្យការអមសាលាដំបូងខេត្តព្រះសីហនុ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាប លោកស្រី ជ្រាបថាផ្អែកតាមកិច្ចសន្យា ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៤ និងលិខិតផ្ទេរសិទ្ធិ ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៤ ខ្ញុំបាទអស់ការទុកចិត្ត និងប្រគល់សិទ្ធិទៀតហើយ ដោយហេតុថា ចាប់តាំងពីខ្ញុំប្រគល់សិទ្ធិ និងចុះកិច្ចសន្យាមក មានរយៈពេល ៥ឆ្នាំ មកហើយតែគ្មានលទ្ធផលការងារ ហើយថែមទាំងលួចធ្វើឯកសារដីរបស់ខ្ញុំទៀតផង លើសពីនេះ លោកស្រី មានជាប់ពាក់ព័ន្ធនឹងបទល្មើសផ្សេងទៀត ជាក់ស្តែងដូចមានក្នុងដីកាបញ្ជាឱ្យចូលខ្លួនលេខ ០១១ អយ ច/២០ ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២០ របស់អយ្យការអមសាលាដំបូងខេត្តព្រះសីហនុ ទៀតផង។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមលោកស្រី មេត្តាជ្រាបតាមការជូនដំណឹងនេះតទៅ និងប្រគល់ឯកសារច្បាប់ដើមដូចជាឯកសារ ដី ផ្ទះ សៀវភៅគ្រួសារ សៀវភៅស្នាក់នៅ និងឯកសារផ្សេងទៀត ។

ថ្ងៃចន្ទ ២កើត ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

ត្រូវនឹងថ្ងៃទី២២ខែមិថុនា ឆ្នាំ ២០២០

ស្នាមមេដៃសាមី

៥ញោះឬខ

ព្រះរាជាណាចក្រកម្ពុជា មេធាវី AVOCAT ATTORNEY AT LAW KINGDOM OF CAMBODIA

មេធាវី.គុំ~ប៊ុនធេន

គង់ សុខសាន្ត

ក) Type [illegible]

— [illegible] ... ថ្ងៃទី20 [illegible] ឆ្នាំ2018 [illegible]

— [illegible] "ក" [illegible]

— [illegible] "ក" [illegible]

[illegible] "ក" [illegible]

— [illegible]

"ក" [illegible]

— [illegible]

10 ខែ 10 ឆ្នាំ2018 [illegible]